# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៤-៦-២០១៤ -ព្រះរាជក្រម នស/រកម/០៦១៤/០១០ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើពិធីសារនៃធម្មនុញ្ញអាស៊ាន ស្តីពីយន្តការដោះស្រាយជម្លោះ ៥៦១៦


### ២~ព្រះរាជក្រឹត្យ


២៣-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១២ ស្តីពី ការតែងតាំង ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី ៣ ចំនួន ០៤ រូប ៥៦៨៦

២៣-៥-២ ០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦១៣ ស្តីពី ការតែងតាំង ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី ៣ ចំនួន ០៥ រូប ៥៦៨៧

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២៣ ស្តីពី ការតែងតាំង ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី ៣ ចំនួន ០៨ រូប ៥៦៨៨

២៦-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦២៤ ស្តីពី ការតែងតាំង ឯកឧត្តម និងលោកជំទាវ ចំនួន ០៧ រូប ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី ៣ ៥៦៨៩

៣១-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៦៤ ស្តីពី ការដាក់ លោកជំទាវ **តាន់ សុខា** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ៥៦៩០

៣១-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៦៥ ស្តីពី ការបញ្ចប់តំណែង ឯកឧត្តម **សូ ខនបញ្ញារិទ្ធិ** ពីសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៥៦៩១

៣១-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៦៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ម៉ឺប៊ឺហ្គើ បេនចាមីន ហ្សង់** (MAUER BERGER BENJAMIN, JEAN) ជនជាតិបារាំង សញ្ជាតិបារាំង កើតនៅក្រុងចូហានីសប៊ើគ ប្រទេសអាហ្វ្រិកខាងត្បូង ដោយប្តូរឈ្មោះជា **បេន ស្ម៊ីត** ( BEN SMITH) ៥៦៩២

៣១-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៦៧ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ចាង វូនហ្វឹង** (ZHANG WENFENG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តឡាវនីញ សាធារណរដ្ឋប្រជាមានិតចិន ដោយប្ដូរឈ្មោះជា **ចាង ហ្វឹង** (ZHANG FENG) ៥៦៩៣

៣១-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៦៨ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **មីស៊ូហ្ស៊ីមា អាគីហ៊ីគតូ** (MIZUSHIMA AKIHIKO) ជនជាតិជប៉ុន សញ្ជាតិជប៉ុន កើតនៅក្រុងហ្វូកូកា (FUKUOKA CITY) ប្រទេសជប៉ុន ដោយប្ដូរឈ្មោះជា **ចេង ពិសិដ្ឋគង្គា** (CHENG PISETHKONGKEA) ៥៦៩៤

## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

១១-៦-២០១៤ -អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ស្ដីពី ធនាគារអភិវឌ្ឍន៍ជនបទ ៥៦៩៥

១២-៦-២០១៤ -អនុក្រឹត្យលេខ ២០០ អនក្រ.បក ស្ដីពី ការបង្កើតនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន នៃក្រសួងសុខាភិបាល ៥៧០០

១៣-៦-២០១៤ -អនុក្រឹត្យលេខ ២០១ អនក្រ.បក ស្ដីពី ឯកសណ្ឋាន ស្លាកសញ្ញា និងសញ្ញាសក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៥៧០៣

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៦៣ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៥៧០៨

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៦៤ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៧១០

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៦៥ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៧១១

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៦៦ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ៥៧១២

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្ដីពី ការតម្លើងឋានៈជូនមន្ត្រីរាជការ ៥៧១៤

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥៧១៦

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្ដីពី ការតែងតាំង និងតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៥៧១៨

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៧២០

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៥៧២១

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៧២២

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៧២៤

## ២-សេចក្ដីសម្រេច

០៩-៦-២០១៤ -សេចក្ដីសម្រេចលេខ ១០៧ សសរ ស្ដីពី ការជ្រើសរើសពលទាហាន ៥៧២៦

០៩-៦-២០១៤ -សេចក្ដីសម្រេចលេខ ១០៨ សសរ ស្ដីពី យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ ៥៧២៧

១៣-៦-២០១៤ -សេចក្ដីសម្រេចលេខ ១០៩ សសរ ស្ដីពី ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី ៨ ស្ដីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ៥៧២៩

១៦-៦-២០១៤ -សេចក្ដីសម្រេចលេខ ១១០ សសរ ស្ដីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៥៧៣២

## III-ការងារបណ្ដាក្រសួង

### ទីស្ដីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៣-៦-២០១៤ -ប្រកាសអន្តរក្រសួងលេខ ៦២៧ សហវ.ប្រក ស្ដីពី ការផ្ដល់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភជូនគណៈកម្មការអន្តរក្រសួងដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលផល-អនុផលព្រៃឈើ ៥៧៣៣

១៧-៦-២០១៤ -ប្រកាសអន្តរក្រសួងលេខ ៦៣៧ សហវ.ប្រក ស្ដីពី ការបង្កើតគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ៥៧៣៦

# ព្រះរាជក្រម

នស/រកម/០៦១៤/០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃធម្មនុញ្ញអាស៊ាន ស្តីពីយន្តការដោះស្រាយជម្លោះ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖



# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារនៃធម្មនុញ្ញអាស៊ាន ស្តីពីយន្តការដោះស្រាយជម្លោះ

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារនៃធម្មនុញ្ញអាស៊ានស្តីពីយន្តការដោះស្រាយជម្លោះ ដែលបានចុះហត្ថលេខា នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម នាថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារនេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៤

នស/រកម.០៦១៤.០៥៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**ហត្ថលេខា**
**ហោ ណាំហុង**

លេខៈ ៧២៦ ស.ណ
**សំណៅចំលងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
**ស៊ុយ សុខា**

*(បកប្រែក្រៅផ្លូវការ)*

# ពិធីសារនៃធម្មនុញ្ញអាស៊ាន
# ស្តីពីយន្តការដោះស្រាយជម្លោះ

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេ ដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិប-តេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ារ សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ-ឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដែលសំដៅជារួមថា "រដ្ឋសមាជិក" ឬសំដៅជាឯកត្តរដ្ឋថា "រដ្ឋសមាជិកនីមួយៗ" ៖

**ដោយគិតដល់** បំណងប្រាថ្នារបស់អ្នកដឹកនាំអាស៊ាន ក្នុងការប្រែក្លាយអាស៊ានឱ្យទៅជាអង្គការមួយដែលផ្អែកលើច្បាប់ ដោយមានយន្តការជាក់ស្តែងប្រកបដោយប្រសិទ្ធិភាព និងគួរឱ្យជឿទុកចិត្ត ដើម្បីដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធិ-ភាព និងទាន់ពេលវេលា។

**ដោយរំលឹកឡើងវិញពី** វាក្យខណ្ឌ២ (ឃ) នៃមាត្រា២នៃធម្មនុញ្ញអាស៊ាន ដែលចែងថា អាស៊ាន និងរដ្ឋសមាជិកត្រូវប្រព្រឹត្តដោយអនុលោមតាមគោលការណ៍ទំនុកចិត្ត ស្តីពីដំណោះស្រាយជម្លោះដោយសន្តិវិធី

**ដោយរំលឹកឡើងវិញបន្ថែមទៀតពី** វាក្យខណ្ឌ២នៃមាត្រា២២នៃធម្មនុញ្ញអាស៊ាន ដែលតម្រូវឱ្យអាស៊ានរក្សា និងបង្កើតយន្តការដោះស្រាយជម្លោះលើគ្រប់វិស័យនៃកិច្ចសហប្រតិបត្តិការអាស៊ាន

**ដោយទទួលស្គាល់ថា** ដោយអនុលោមតាមមាត្រា២៥នៃធម្មនុញ្ញអាស៊ាន ប្រសិនបើពុំមានការបញ្ជាក់ផ្ទុយពីនេះ យន្តការដោះស្រាយជម្លោះសមស្រប នឹងត្រូវបង្កើតឡើងសម្រាប់ជម្លោះដែលពាក់ព័ន្ធដល់ការបកស្រាយ ឬការអនុវត្តន៍ធម្មនុញ្ញអាស៊ាននេះ និងលិខិតុបករណ៍អាស៊ានផ្សេងទៀត និង

**ដោយមានជំនឿថា** ការមានយន្តការដោះស្រាយជម្លោះដែលគួរឱ្យជឿទុកចិត្ត នឹងជួយអាស៊ានទប់ស្កាត់ជម្លោះរាលដាល និងការប្រឈមមុខក្នុងចំណោមរដ្ឋសមាជិក ដោយរក្សាបរិយាកាសសហប្រតិបត្តិការ ដើម្បីកិច្ចខិតខំប្រឹងប្រែងរួមគ្នាឆ្ពោះទៅការកសាងសហគមន៍អាស៊ានប្រកបដោយសន្តិភាព និងវិបុលភាព។

**បានឯកភាពដូចខាងក្រោម ៖**

## មាត្រា១
## និយមន័យ

សម្រាប់គោលបំណងនៃពិធីសារនេះ:

(ក) **លិខិតុបករណ៍អាស៊ាន** មានន័យថា លិខិតុបករណ៍ណាមួយ ដែលត្រូវបានសម្រេចដោយរដ្ឋសមាជិក ដែលជារដ្ឋសមាជិកអាស៊ាន ក្នុងទម្រង់បែបបទជាលាយលក្ខណ៍អក្សរដែលបណ្តាលឱ្យមានសិទ្ធិ និងកាតព្វកិច្ចរៀងៗខ្លួន ដោយអនុលោមតាមច្បាប់អន្តរជាតិ

(ខ) ភាគីតវ៉ា មានន័យថា រដ្ឋសមាជិកណាមួយដែលស្នើសុំឱ្យមានការពិគ្រោះយោបល់ក្រោមមាត្រា៥ នៃពិធីសារនេះ
(គ) ភាគីឆ្លើយតប មានន័យថា រដ្ឋសមាជិកណាមួយ ដែលសំណើសុំការពិគ្រោះយោបល់ត្រូវបានគេធ្វើឡើងក្រោមមាត្រា៥នៃពិធីសារនេះ
(ឃ) **ភាគីនៃជម្លោះ** មានន័យថា ភាគីតវ៉ា និងភាគីឆ្លើយតប និង
(ង) **ជម្លោះមិនត្រូវបានដោះស្រាយ** មានន័យថា ជម្លោះលើការបកស្រាយ ឬការអនុវត្តន៍ធម្មនុញ្ញអាស៊ាន ឬក៏លិខិតុបករណ៍អាស៊ានផ្សេងទៀត ដែលខកខានមិនបានដោះស្រាយដោយការព្រមព្រៀងគ្នាទៅវិញទៅមក បន្ទាប់ពីការអនុវត្តន៍ និងការប្រតិបត្តិមាត្រា៩នៃពិធីសារនេះ។

## មាត្រា២
## វិសាលភាព និងការអនុវត្តន៍

១. ពិធីសារនេះ ត្រូវអនុវត្តចំពោះជម្លោះទាំងឡាយ ដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍នៃ ៖
(ក) ធម្មនុញ្ញអាស៊ាន
(ខ) លិខិតុបករណ៍អាស៊ានផ្សេងទៀត លើកលែងតែមធ្យោបាយជាក់លាក់សម្រាប់ដោះស្រាយជម្លោះទាំងនោះត្រូវបានចែងរួចហើយ។
(គ) លិខិតុបករណ៍អាស៊ានផ្សេងទៀត ដែលមានចែងយ៉ាងច្បាស់ថា ពិធីសារនេះ ឬផ្នែកនៃពិធីសារនេះ នឹងត្រូវយកមកអនុវត្ត។

២. វាក្យខណ្ឌ១ (ខ) នៃមាត្រានេះនឹងយកទៅអនុវត្ត ដោយគ្មានការលំអៀងចំពោះសិទ្ធិរបស់ភាគីនៃជម្លោះទាំងនោះឱ្យព្រមព្រៀងទៅវិញទៅមកថា ពិធីសារនេះត្រូវអនុវត្ត។

## មាត្រា៣
## បទប្បញ្ញត្តិទូទៅ

១. ពិធីសារនេះនឹងត្រូវបកស្រាយដោយអនុលោមតាមវិធានជាទម្លាប់នៃការបកស្រាយសន្ធិសញ្ញា នៃច្បាប់អន្តរជាតិសាធារណៈ។

២. ភាគីទាំងឡាយ ដែលមានជម្លោះត្រូវបានលើកទឹកចិត្តគ្រប់ដំណាក់កាលនៃជម្លោះ ឱ្យខិតខំប្រឹងប្រែង ដើម្បីឈានដល់ដំណោះស្រាយដែលបានឯកភាពគ្នាទៅវិញទៅមក។ ដរាបណាសម្រេចបានដំណោះស្រាយដែលបានឯកភាពគ្នាទៅវិញទៅមក ត្រូវជូនព័ត៌មានទៅអគ្គលេខាធិការអាស៊ាន និងរដ្ឋសមាជិកដទៃទៀត។

## មាត្រា៤
## ការប្រាស្រ័យទាក់ទងគ្នា និងថេរវេលា

១. ការប្រាស្រ័យទាក់ទងគ្នា ក្នុងនោះរួមមានការជូនដំណឹង សំណូមពរ ការឆ្លើយតប និងលិខិតបញ្ជាក់ "ជាលាយលក្ខណ៍អក្សរ" ដែលធ្វើឡើងយោងទៅតាមពិធីសារនេះ ហើយត្រូវសន្មតថាត្រូវបានទទួល ប្រសិនបើឯកសារទាំងនេះត្រូវបានផ្ញើទៅកាន់ភាគីទទួល តាមរយៈបណ្តាញការទូត។

២. ក្នុងករណី ដែលពុំមានការកំណត់ជាក់លាក់ទេនោះ ថេរវេលាដែលមានកំណត់នៅក្នុងពិធីសារនេះ មិនត្រូវមានការកែប្រែដោយកិច្ចព្រមព្រៀងរួមគ្នារបស់ភាគីនៃជម្លោះឡើយ។

## មាត្រា៥
## ការពិគ្រោះយោបល់

១. ភាគីតវ៉ាអាចស្នើឱ្យមានការពិគ្រោះយោបល់ជាមួយភាគីឆ្លើយតបដោយអាស្រ័យទៅលើជម្លោះទាំងឡាយណា ដែលទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តន៍ធម្មនុញ្ញអាស៊ាន ឬលិខិតុបករណ៍អាស៊ានផ្សេងទៀត។ ភាគីឆ្លើយតបត្រូវយល់ព្រមធ្វើការពិចារណាសមស្របចំពោះសំណើ ឱ្យមានការពិគ្រោះយោបល់ដែលធ្វើឡើងដោយភាគីតវ៉ា និងត្រូវផ្តល់ឱកាសគ្រប់គ្រាន់ សម្រាប់ការពិគ្រោះយោបល់បែបនេះ។

២. សំណើសុំឱ្យមានការពិគ្រោះយោបល់ត្រូវបញ្ជាក់ពីហេតុផលសម្រាប់ការស្នើសុំ ក្នុងនោះរួមមាន ការកំណត់អត្តសញ្ញាណនៃបញ្ហាដែលបណ្តាលអោយមានជម្លោះ និងការបង្ហាញពីមូលដ្ឋានផ្លូវច្បាប់នៃបណ្តឹងតវ៉ា។ សេចក្តីចម្លងនៃសំណើបែបនេះ នឹងត្រូវប្រគល់ជូនក្នុងពេលជាមួយគ្នាទៅអគ្គលេខាធិការអាស៊ាន ដែលនឹងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់រដ្ឋសមាជិកទាំងអស់អំពីសំណើបែបនេះ។

៣. បើសិនជាសំណើសុំឱ្យមានការពិគ្រោះយោបល់ត្រូវបានធ្វើឡើង ភាគីឆ្លើយតបត្រូវឆ្លើយតបទៅនឹងសំណើនេះ ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលសំណើនេះ ហើយត្រូវចូលរួមក្នុងកិច្ចពិគ្រោះយោបល់ ក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលសំណើសម្រាប់ការពិគ្រោះយោបល់នេះ ដើម្បីឈានទៅរកដំណោះស្រាយរួមមួយ។ កិច្ចពិគ្រោះយោបល់ត្រូវបញ្ចប់ ក្នុងរយៈពេល ៩០ថ្ងៃ ឬក្នុងថេរវេលាណាមួយ ដែលភាគីជម្លោះបានព្រមព្រៀងគ្នា ដោយគិតចាប់តាំងពីថ្ងៃបានទទួលសំណើសម្រាប់កាពិគ្រោះយោបល់។

## មាត្រា៦
## ការសម្របសម្រួល សន្ធានកម្ម និងការផ្សះផ្សា

១. ភាគីនៃជម្លោះអាចយល់ព្រមឱ្យមានការសម្របសម្រួល សន្ធានកម្ម ឬការផ្សះផ្សានៅពេលណាក៏បាន។ នីតិវិធីនៃការសម្របសម្រួល សន្ធានកម្ម ឬការផ្សះផ្សាអាចចាប់ផ្តើម និងបញ្ចប់ពេលណាក៏បាន។

២. ភាគីនៃជម្លោះអាចស្នើប្រធានអាស៊ាន ឬអគ្គលេខាធិការអាស៊ានឱ្យបំពេញតួនាទីពេញច្បាប់ ដើម្បីផ្តល់ការសម្របសម្រួល សន្ធានការី ឬអ្នកផ្សះផ្សា។

៣. នីតិវិធីពាក់ព័ន្ធនឹងការសម្របសម្រួល សន្ធានកម្ម ឬការផ្សះផ្សា និងគោលជំហរដែលលើកឡើងដោយគ្រប់ភាគីនៃជម្លោះក្នុងដំណើរការនៃនីតិវិធីទាំងនេះ មិនត្រូវធ្វើឱ្យមានព្យសនកម្មដល់សិទ្ធិរបស់គ្រប់ភាគីនៃជម្លោះ ឬប៉ះពាល់ដល់នីតិវិធីផ្សេងទៀតឡើយ។

៤. (ក) យោងទៅតាមមាត្រា៩នៃពិធីសារនេះ ការសម្របសម្រួល សន្ធានកម្ម ឬការផ្សះផ្សា ត្រូវដឹកនាំដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ត្រូវអនុលោមទៅតាមវិធាននៃការសម្របសម្រួល សន្ធានកម្ម ឬវិធាននៃការផ្សះផ្សា ដែលត្រូវធ្វើការកែប្រែបែបនេះ នៅពេលដែលភាគីនៃជម្លោះអាចយល់ព្រមជាលាយលក្ខណ៍អក្សរ។

(ខ) នីតិវិធីនៃការសម្របសម្រួល សន្ធានកម្ម ឬការផ្សះផ្សា ដឹកនាំដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយយោងទៅតាមមាត្រា៩នៃពិធីសារនេះ ត្រូវអនុលោមទៅតាមវិធាននៃការសម្របសម្រួល វិធាននៃសន្ធានកម្ម ឬវិធាននៃការផ្សះផ្សា ដែលត្រូវធ្វើការកែប្រែនីតិវិធី នៅពេលដែលភាគីនៃជម្លោះអាចយល់ព្រមជាលាយលក្ខណ៍អក្សរ។

## មាត្រា៧
## មុខងារនៃការសម្របសម្រួល សន្ធានកម្ម និងការផ្សះផ្សា

១. បុគ្គលដែលផ្តល់ការសម្របសម្រួល សន្ធានកម្ម ឬការផ្សះផ្សាត្រូវជួយ និងជួយសម្រួលដល់ភាគីនៃជម្លោះ ដើម្បីសម្រេចបាននូវដំណោះស្រាយមួយប្រកបដោយមិត្តភាពរវាងពួកគេ ដោយយោងទៅតាមបញ្ញត្តិនៃធម្មនុញ្ញអាស៊ាន និង/ឬ លិខិតុបករណ៍អាស៊ានផ្សេងទៀត។

២. នៅពេលដែលភាគីនៃជម្លោះសម្រេចបានដំណោះស្រាយប្រកបដោយមិត្តភាព ភាគីនៃជម្លោះត្រូវតាក់តែង និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយជម្លោះជាលាយលក្ខណ៍អក្សរ។

៣. តាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយជម្លោះ ភាគីនៃជម្លោះបានបញ្ចប់ជម្លោះ ហើយត្រូវចងកាតព្វកិច្ចតាមរយៈកិច្ចព្រមព្រៀងនោះ។

៤. ភាគីនៃជម្លោះត្រូវជូនដំណឹងពីកិច្ចព្រមព្រៀងដោះស្រាយជម្លោះដល់អគ្គលេខាធិការអាស៊ាន រដ្ឋសមាជិកដទៃទៀត និងក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន នៅពេលណាដែលការសម្របសម្រួល សន្ធានកម្ម ឬការផ្សះផ្សាត្រូវបានដឹកនាំដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន។

## មាត្រា៨
## សំណើឱ្យមានមជ្ឈត្តវិនិច្ឆ័យ

១. តាមរយៈការបញ្ជាក់ជាលាយលក្ខណ៍អក្សរដែលផ្ញើជូនភាគីឆ្លើយតប ភាគីតវ៉ាអាចស្នើឱ្យមានការបង្កើតមជ្ឈត្តវិនិច្ឆ័យដើម្បីដោះស្រាយជម្លោះ ប្រសិនបើ ៖

(ក) ភាគីឆ្លើយតបមិនបានឆ្លើយតបក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលការស្នើសុំឱ្យមានកិច្ចពិគ្រោះយោបល់

(ខ) ភាគីឆ្លើយតបមិនបានចូលរួមក្នុងកិច្ចពិគ្រោះយោបល់ក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីថ្ងៃទទួលការស្នើសុំឱ្យមានកិច្ចពិគ្រោះយោបល់ ឬ

(គ) កិច្ចពិគ្រោះយោបល់ខកខានមិនបានដោះស្រាយជម្លោះ ក្នុងរយៈពេល ៩០ថ្ងៃ ឬក្នុងថេរវេលាណាមួយដែលភាគីនៃជម្លោះបានព្រមព្រៀងគ្នា ចាប់ពីថ្ងៃទទួលការស្នើសុំពិគ្រោះយោបល់

២. សេចក្តីចម្លងមួយច្បាប់នៃសេចក្តីជូនដំណឹងនេះ ត្រូវប្រគល់ជូនអគ្គលេខាធិការអាស៊ាន ដែលមានភារកិច្ចជូនដំណឹងទៅប្រទេសសមាជិកទាំងអស់អំពីសំណើនេះ។ សេចក្តីជូនដំណឹងត្រូវបញ្ជាក់ពីខ្លឹមសារសង្ខេបនៃមូលដ្ឋានខាងផ្លូវច្បាប់ និងអង្គហេតុនៃសំណើសុំដែលមានលក្ខណៈពេញលេញ ដើម្បីបញ្ជាក់បញ្ហាឱ្យច្បាស់លាស់បាន ក្នុងនោះរួមមាន បញ្ញត្តិនៃធម្មនុញ្ញអាស៊ាន ឬលិខិតុបករណ៍អាស៊ាន ដែលត្រូវដោះស្រាយដោយមជ្ឈត្តវិនិច្ឆ័យ។

៣. ភាគីឆ្លើយតបត្រូវបញ្ជាក់ពីការយល់ព្រមចំពោះការបង្កើតមជ្ឈត្តវិនិច្ឆ័យ ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលព័ត៌មានពីភាគីតវ៉ា។ ភាគីនៃជម្លោះអាចព្រមព្រៀងគ្នា ដើម្បីពន្យាពេលសម្រាប់ភាគីឆ្លើយតបបញ្ជាក់ពីការយល់ព្រមរបស់ខ្លួន រហូតដល់ ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលព័ត៌មានពីភាគីតវ៉ា។ សេចក្តីចម្លងនៃការឆ្លើយតបដែលត្រូវបានផ្ញើចេញត្រូវប្រគល់ជូនអគ្គលេខាធិការអាស៊ាន ដែលមានភារកិច្ចជូនព័ត៌មានដល់ប្រទេសសមាជិកអាស៊ានទាំងអស់អំពីការឆ្លើយតបនេះ។

៤. ក្នុងករណីដែលភាគីឆ្លើយតបមិនយល់ព្រមចំពោះសំណើឱ្យបង្កើតមជ្ឈត្តវិនិច្ឆ័យ ឬខកខានមិនបានឆ្លើយតបតាមថេរវេលា ដូចដែលមានកំណត់នៅក្នុងវាក្យខណ្ឌ៣នៃមាត្រានេះ ភាគីតវ៉ាអាចដាក់ករណីនៃជម្លោះទៅក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន។

## មាត្រា៩
## ការដាក់រឿងក្តីទៅកាន់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន

១. ក្នុងករណីដែលជម្លោះដែលត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយយោងទៅតាមវាក្យខ័ណ្ឌ៤ នៃមាត្រា៨ ក្រុមប្រឹក្សាសម្របសម្រួលអាចដឹកនាំភាគីនៃជម្លោះ ដើម្បីដោះស្រាយជម្លោះតាមរយៈការសម្របសម្រួល សន្ធានកម្ម ការផ្សះផ្សា ឬមជ្ឈត្តវិនិច្ឆ័យ។

២. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការសម្រេចចិត្តរបស់ខ្លួនទៅភាគីជម្លោះ ក្នុងរយៈពេល ៤៥ថ្ងៃ គិតចាប់ពីថ្ងៃដែលជម្លោះត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន។ ប្រធានក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវកំណត់អំពីនីតិវិធីធ្វើសេចក្តីសម្រេចរបស់ខ្លួន។ នីតិវិធីបែបនេះអាចរួមបញ្ចូលទាំងកិច្ចពិគ្រោះយោបល់ទាំងឡាយ តាមរយៈលិខិតឆ្លើយឆ្លង អ៊ីម៉ែល ការធ្វើសន្និសីទតាមរយៈវីដេអូ (video-conferencing) ឬមធ្យោបាយផ្សេងៗទៀត។ នៅក្នុងកាលៈទេសៈជាអញ្ញត្រកម្មណាមួយ ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានអាចសម្រេចធ្វើការប្រជុំពិសេសបន្ទាន់មួយរបស់ខ្លួន ដើម្បីសម្រេចលើជម្លោះនោះ។

៣. ក្នុងករណីដែលក្រុមប្រឹក្សាសម្របសម្រួលអាស៊ានយល់ឃើញថា មិនអាចឈានដល់ការធ្វើសេចក្តីសម្រេចចិត្តលើជម្លោះនោះក្នុងអំឡុងពេលដែលបានបញ្ជាក់នៅក្នុងវាក្យខ័ណ្ឌ២នៃមាត្រានេះ ដើម្បីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីជម្លោះពីការសម្រេចចិត្តរបស់ខ្លួន។ ក្រុមប្រឹក្សានេះអាចធ្វើការសម្រេចពន្យាពេលបានមួយរយៈកាល តែមិនត្រូវលើសពី ៣០ថ្ងៃ ឡើយ ហើយត្រូវជូនដំណឹងនោះទៅភាគីជម្លោះ ទៅតាមស្ថានភាពជាក់ស្តែង។

៤. ក្នុងករណីដែលក្រុមប្រឹក្សាសម្របសម្រួលអាស៊ានមិនអាចឈានដល់ការធ្វើសេចក្តីសម្រេច ថាតើជម្លោះត្រូវដោះស្រាយយ៉ាងដូចម្តេច ក្នុងរយៈពេលដែលបានបញ្ជាក់នៅក្នុងវាក្យខ័ណ្ឌ២នៃមាត្រានេះ ដើម្បីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីជម្លោះអំពីការសម្រេចចិត្តរបស់ខ្លួន ឬអាចពន្យាពេលជាក់លាក់មួយបាន។ ភាគីជម្លោះមួយណាក៏អាចបញ្ជូនជម្លោះនោះទៅកិច្ចប្រជុំកំពូលអាស៊ាន ក្នុងលក្ខណៈជាជម្លោះមិនទាន់ត្រូវបានដោះស្រាយ ដូចដែលមានចែងនៅក្នុងមាត្រា២៦នៃធម្មនុញ្ញអាស៊ាន ។

## មាត្រា១០
## មជ្ឈត្តវិនិច្ឆ័យ

១. មជ្ឈត្តវិនិច្ឆ័យដែលចេញពីការយល់ព្រមពីភាគីនៃជម្លោះ ឬតាមការណែនាំរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវអនុលោមទៅតាមពិធីសារនេះ និងវិធាននៃមជ្ឈត្តវិនិច្ឆ័យ ដែលជាឧបសម្ព័ន្ធនៃពិធីសារនេះ។

២. និតិវិធីរបស់មជ្ឈត្តវិនិច្ឆ័យត្រូវអនុលោមទៅនឹងវិធាននៃមជ្ឈត្តវិនិច្ឆ័យ ដែលជាឧបសម្ព័ន្ធនៃពិធីសារនេះ អាចនឹងត្រូវធ្វើការកែប្រែ នៅពេលដែលភាគីនៃជម្លោះអាចយល់ព្រមជាលាយលក្ខណ៍អក្សរ។

## មាត្រា១១
## មជ្ឈត្តករ

១. លក្ខណៈសម្បត្តិ និងចំនួនមជ្ឈត្តករ ដែលត្រូវតែងតាំង ឬត្រូវជំនួស ត្រូវមានចែងនៅក្នុងវិធាននៃមជ្ឈត្តវិនិច្ឆ័យ ដែលជាឧបសម្ព័ន្ធនៃពិធីសារនេះ។

២. មជ្ឈត្តករទាំងអស់ត្រូវ ៖

(ក) មានជំនាញ ឬមានបទពិសោធន៍ផ្នែកច្បាប់ បញ្ហាផ្សេងទៀតដែលគ្របដណ្តប់ដោយធម្មនុញ្ញអាស៊ាន ឬលិខិតុបករណ៍អាស៊ានពាក់ព័ន្ធដទៃទៀត ឬដំណោះស្រាយជម្លោះ ដែលស្ថិតនៅក្រោមយុត្តាធិការនៃកិច្ចព្រមព្រៀងអន្តរជាតិ

(ខ) ត្រូវជ្រើសរើសដោយហ្មត់ចត់ ដោយឈរលើមូលដ្ឋានសត្យានុម័ត ភាពគួរឱ្យទុកចិត្ត និងប្រកបដោយសុភនិច្ឆ័យ

(គ) មានឯករាជ្យភាព មិនជាប់ទាក់ទិនជាមួយ ឬទទួលយកការណែនាំពីភាគីនៃជម្លោះណាមួយឡើយ

(ឃ) មិនមានជាប់ពាក់ព័ន្ធជាមួយបញ្ហានេះ ក្នុងកម្រិតណាមួយឡើយ

(ង) បង្ហាញជូនភាគីនៃជំលោះនូវព័ត៌មានដែលអាចបណ្តាលអោយមានមន្ទិលសង្ស័យ និងដែលជាឯករាជ្យភាព ឬមិនលំអៀងរបស់គេ

៣. ប្រធានមជ្ឈត្តវិនិច្ឆ័យមិនត្រូវមានសញ្ជាតិភាគីនៃជម្លោះណាមួយឡើយ ហើយត្រូវជាពលរដ្ឋនៃរដ្ឋសមាជិកណាមួយ។

## មាត្រា១២
## មុខងាររបស់មជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើការពិនិត្យលើអង្គហេតុនៃបណ្តឹងនោះ ហើយត្រូវវិនិច្ឆ័យករណីនេះ ដោយយោងទៅតាមបទប្បញ្ញត្តិនៃធម្មនុញ្ញអាស៊ាន និង/ឬលិខិតុបករណ៍អាស៊ានដែលបានអះអាងដោយភាគីជម្លោះ ដើម្បីធ្វើការដោះស្រាយជម្លោះរវាងពួកគេ ហើយត្រូវផ្តល់ហេតុផលសម្រាប់ការវិនិច្ឆ័យរបស់ខ្លួន។

## មាត្រា១៣
## ភាគីទី៣

១. រដ្ឋសមាជិកណាមួយដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរពីចំណាប់អារម្មណ៍លើខ្លឹមសារនៃជម្លោះ ក្នុងរយៈពេល ៣០ថ្ងៃ ចាប់តាំងពីការជូនដំណឹងជាលាយលក្ខណ៍អក្សរពីចម្លើយនៃភាគីឆ្លើយតប ដែលយល់ព្រមចំពោះសំណើបង្កើតមជ្ឈត្តវិនិច្ឆ័យ យោងទៅតាមវាក្យខណ្ឌ៣ នៃមាត្រា៨ ឬការជូនដំណឹងជាលាយលក្ខណ៍អក្សរពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដែលដឹកនាំភាគីនៃជម្លោះដើម្បីដោះស្រាយជម្លោះ តាមរយៈមជ្ឈត្តវិនិច្ឆ័យដោយយោងទៅតាមមាត្រា៩ ត្រូវមានសិទ្ធិ និងកាតព្វកិច្ចនៃភាគីទីបី។

២. ភាគីទីបីត្រូវមានឱកាសចូលរួមផ្តល់សក្ខីកម្មក្នុងការដោះស្រាយជម្លោះ ដោយមជ្ឈត្តវិនិច្ឆ័យ ហើយអាចដាក់សំណើពិនិត្យសម្រេចទៅមជ្ឈត្តវិនិច្ឆ័យ។ ការស្នើសុំពិនិត្យសម្រេច ត្រូវផ្តល់ឱ្យភាគីនៃជម្លោះផងដែរ និងត្រូវឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ។

៣. ភាគីទីបីត្រូវទទួលពីភាគីនៃជម្លោះនូវឯកសារសំណើរបស់ភាគីនៃជម្លោះ ចំពោះកិច្ចប្រជុំបឋមរបស់មជ្ឈត្តវិនិច្ឆ័យ។

## មាត្រា១៤
## ច្បាប់ដែលត្រូវអនុវត្ត

១. មជ្ឈត្តវិនិច្ឆ័យត្រូវអនុវត្តរាល់បទប្បញ្ញត្តិនៃធម្មនុញ្ញអាស៊ាន និងលិខិតុបករណ៍អាស៊ានដទៃទៀត ព្រមទាំងវិធាននៃច្បាប់អន្តរជាតិសាធារណៈដែលត្រូវអនុវត្ត។

២. មជ្ឈត្តនិថ្ម័យត្រូវអនុវត្តវិធាននៃច្បាប់ដទៃទៀតដែលត្រូវអនុវត្តចំពោះបញ្ហាជាគន្លឹះនៃជម្លោះ ឬវិនិច្ឆ័យរឿងក្តី យោងទៅតាមសមធម៌ និងមនសិការ ប្រសិនបើបានយល់ព្រមយ៉ាងដូច្នោះ ដោយភាគីនៃជម្លោះ។

## មាត្រា១៥
## សេចក្តីសម្រេចរបស់មជ្ឈត្តករ

១. សេចក្តីសម្រេចរបស់មជ្ឈត្តករជាការសម្រេចជាចុងក្រោយ និងជាកាតព្វកិច្ចខាងផ្លូវច្បាប់ចំពោះភាគីនៃជម្លោះ។ សេចក្តីសម្រេចនឹងត្រូវអនុវត្តយ៉ាងពេញលេញដោយភាគីនៃជម្លោះ។

២. សេចក្តីសម្រេចរបស់មជ្ឈត្តករនឹងមិនត្រូវបន្ថែម ឬបន្ថយសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន ឬលិខិតុបករណ៍អាស៊ានពាក់ព័ន្ធដទៃទៀត។

## មាត្រា១៦
## ការអនុវត្តន៍ការសម្រេចរបស់មជ្ឈត្តករ និងកិច្ចព្រមព្រៀងដោះស្រាយជម្លោះ

១. ភាគីនៃជម្លោះត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់មជ្ឈត្តករ និងកិច្ចព្រមព្រៀងដោះស្រាយដែលជាលទ្ធផលទទួលបានពីការសម្របសម្រួល សន្ទានកម្ម និងការផ្សះផ្សា។

២. ភាគីនៃជម្លោះណាមួយដែលតម្រូវឱ្យអនុវត្តតាមសេចក្តីសម្រេចរបស់មជ្ឈត្តករ ឬកិច្ចព្រមព្រៀងដោះស្រាយជម្លោះត្រូវផ្តល់របាយការណ៍ជូនអគ្គលេខាធិការអាស៊ានជាលាយលក្ខណ៍អក្សរ ក្នុងការអនុវត្តន៍តាមសេចក្តីសម្រេចរបស់មជ្ឈត្តករ ឬកិច្ចព្រមព្រៀងដោះស្រាយជម្លោះ។

## មាត្រា១៧
## ការចំណាយ

១. ការចំណាយផ្សេងៗរបស់មជ្ឈត្តនិថ្ម័យដែលស្ថិតនៅក្រោមពិធីសារនេះ នឹងត្រូវទទួលបន្ទុកដោយភាគីនៃជម្លោះ ដោយអនុលោមតាមវិធាននៃមជ្ឈត្តនិថ្ម័យ ដែលជាឧបសម្ព័ន្ធនៃពិធីសារនេះ។

២. ការចំណាយលើការសម្របសម្រួល សន្ទានកម្ម និងការផ្សះផ្សា នឹងត្រូវកំណត់ដោយអ្នកធ្វើការសម្របសម្រួល សន្ទានកម្ម និងការផ្សះផ្សា ដោយពិភាក្សា និងមានការព្រមព្រៀងដោយភាគីនៃជម្លោះ ហើយភាគីនៃជម្លោះត្រូវចេញលើការចំណាយនោះស្មើៗគ្នា។ ការចំណាយផ្សេងទៀតដែលធ្វើឡើងដោយភាគីនៃជម្លោះណាមួយ គឺជាបន្ទុករបស់ភាគីនោះ។

## មាត្រា១៨
## មុខងាររបស់លេខាធិការដ្ឋានអាស៊ាន

១. លេខាធិការដ្ឋានអាស៊ានត្រូវមានការទទួលខុសត្រូវក្នុងការជួយដល់មជ្ឈត្តនិថ្ម័យ និងអ្នកទទួលបន្ទុកក្នុងការសម្របសម្រួល សន្ទានកម្ម និងការផ្សះផ្សា ជាពិសេសលើទិដ្ឋភាពផ្នែកច្បាប់ ប្រវត្តិសាស្ត្រ និងនីតិវិធី ក្នុងការស្វែងរកការដោះស្រាយ ព្រមទាំងផ្តល់ការគាំទ្រផ្នែកលេខាធិការដ្ឋាន និងបច្ចេកទេសផងដែរ។

២. ការចំណាយផ្សេងៗ លើការគាំទ្ររបស់លេខាធិការដ្ឋានអាស៊ាន ជាបន្ទុករបស់ភាគីនៃជម្លោះ។

## មាត្រា១៩
## អនុសាសន្តិប្បញ្ញត្តិ

១. ពិធីសារនេះត្រូវចុះហត្ថលេខាដោយរដ្ឋសមាជិកទាំងអស់។

២. ពិធីសារនេះត្រូវផ្តល់សច្ចាប័នដោយរដ្ឋសមាជិកទាំងអស់ ដោយអនុលោមទៅតាមនិតិវិធីផ្ទៃក្នុងរបស់ខ្លួន។

៣. លិខិតុបករណ៍ស្តីពីការផ្តល់សច្ចាប័នត្រូវតម្កល់ទុកនៅអគ្គលេខាធិការអាស៊ាន ដែលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការតម្កល់ទុកលិខិតុបករណ៍នេះ ទៅរដ្ឋសមាជិកនីមួយៗ។

៤. ពិធីសារនេះត្រូវចូលជាធរមានបន្ទាប់ពីអគ្គលេខាធិការអាស៊ានបានទទួលលិខិតុបករណ៍ទីដប់ នៃការផ្តល់សច្ចាប័ន។

៥. ពិធីសារនេះត្រូវបានតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ហើយអគ្គលេខាធិការអាស៊ានត្រូវផ្តល់ឯកសារថតចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវទៅរដ្ឋសមាជិកនីមួយៗភ្លាម។

## មាត្រា២០
## ឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធទាំងអស់នៃពិធីសារនេះត្រូវធ្វើឡើងជាផ្នែកដែលមិនអាចកាត់ផ្តាច់បានពីពិធីសារនេះ។

២. ក្នុងករណីមានវិវាទរវាងពិធីសារនេះជាមួយនឹងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយពិធីសារនេះ ត្រូវយកមកអនុវត្តជាផ្លូវការ។

## មាត្រា២១
## វិសោធនកម្ម

១. រដ្ឋសមាជិកណាមួយអាចស្នើសុំធ្វើវិសោធនកម្មលើពិធីសារនេះ និង/ឬ ឧបសម្ព័ន្ធណាមួយ ទៅគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន។

២. ការធ្វើវិសោធនកម្មដែលបានស្នើចំពោះពិធីសារនេះ និង/ឬ ឧបសម្ព័ន្ធណាមួយ ត្រូវធ្វើឡើងដោយកុងសង់ស៊ុស ហើយត្រូវដាក់ជូនក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន។

៣. ការធ្វើវិសោធនកម្មលើពិធីសារនេះ និង/ឬ ឧបសម្ព័ន្ធណាមួយ ដែលត្រូវបានអនុម័តដោយកុងសង់ស៊ុស នៃក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន នឹងត្រូវផ្តល់សច្ចាប័នដោយរដ្ឋសមាជិកទាំងអស់ ដោយអនុលោមតាមនីតិវិធីផ្ទៃក្នុងរៀងៗខ្លួន។

៤. ការធ្វើវិសោធនកម្មត្រូវចូលជាធរមាន ៣០ថ្ងៃ បន្ទាប់ពីអគ្គលេខាធិការអាស៊ានបានទទួលលិខិតុបករណ៍ទីដប់ ស្តីពីការផ្តល់សច្ចាប័ន។

ជាសក្ខីកម្មនៅទីនេះ ហត្ថលេខីដែលបានចុះហត្ថលេខាលើពិធីសារនៃធម្មនុញ្ញអាស៊ានស្តីពីយន្តការដោះស្រាយជម្លោះនេះ ត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលនៃប្រទេសសមាជិកនីមួយៗ។

ធ្វើនៅហាណូយ ប្រទេសវៀតណាម ថ្ងៃទីប្រាំបី ខែមេសា ឆ្នាំពីរពាន់ដប់ តែមួយច្បាប់គត់ជាភាសាអង់គ្លេស។

តំណាងប្រ៊ុយណេដារូសាឡាម

**មហាមេដ ប៊ុលគា**
**រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្ម**

តំណាងព្រះរាជាណាចក្រកម្ពុជា

**ហោ ណាំហុង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

តំណាងសាធារណរដ្ឋឥណ្ឌូនេស៊ី

**បណ្ឌិត រ.ម. ម៉ាទី ម.ណាតាលីហ្គាវ៉ា**
**រដ្ឋមន្ត្រីការបរទេស**

តំណាងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

**បណ្ឌិត ថុងលុន ស៊ីសុលីត**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស**

តំណាងម៉ាឡេស៊ី

**តាន ស្រី រ៉ាសតាម ម៉ូដ អ៊ីសា**
**អគ្គលេខាធិការ**

តំណាងសហភាពមីយ៉ាន់ម៉ារ

**ញៀន វីន**
**រដ្ឋមន្ត្រីការបរទេស**

តំណាងសាធារណរដ្ឋហ្វីលីពីន

**អេលីនដា បាស៊ីល្យូ**
**អនុរដ្ឋលេខាធិការ នាយកដ្ឋានកិច្ចការបរទេស**

តំណាងសាធារណរដ្ឋសឹង្ហបុរី

**ជូច យ៉ុង-ប៊ូន យូច**
**រដ្ឋមន្ត្រីការបរទេស**

តំណាងព្រះរាជាណាចក្រថៃឡង់ដ៍

**កាស៊ីត ភីរម្យយ៉ា**
**រដ្ឋមន្ត្រីការបរទេស**

តំណាងសាធារណរដ្ឋសង្គមនិយមវៀតណាម

**បណ្ឌិត ផាម យ៉ា ឃៀម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស**

(សេចក្ដីបកប្រែក្រៅផ្លូវការ)

ឧបសម្ព័ន្ធ១

# វិធានស្ដីពីការសម្របសម្រួល

**វិធានទី ១ ៖ ការចាប់ផ្ដើម**

១. ក្នុងករណីដែលក្រុមប្រឹក្សាសម្របសម្រួលអាស៊ានចេញសេចក្ដីបង្គាប់ថា ជម្លោះត្រូវដោះស្រាយតាមរយៈការសម្របសម្រួល នោះក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវស្នើប្រធានអាស៊ាន ឬអគ្គលេខាធិការអាស៊ាន ដែលបំពេញតួនាទីសមត្ថកិច្ចផ្លូវការ ឬបុគ្គលដែលមានលក្ខណសម្បត្តិសមស្រប អោយផ្ដល់ការសម្របសម្រួល។ ឯកសារយោងនៅក្នុងវិធានទាំងនេះដែលត្រូវអនុវត្តចំពោះ "បុគ្គលដែលផ្ដល់ការសម្របសម្រួល" និងត្រូវធ្វើការបកស្រាយ ដើម្បីបន្ថែមបុគ្គលដែលត្រូវការផ្ដល់ការសម្របសម្រួល ក្នុងករណីដែលបុគ្គលផ្ដល់ការសម្របសម្រួលលើសពីមួយនាក់។

២. បុគ្គលដែលផ្ដល់ការសម្របសម្រួល ត្រូវទាក់ទងដោយផ្ទាល់ជាមួយភាគីនៃជម្លោះ ដែលនឹងត្រូវផ្ដល់ឲ្យបុគ្គលរូបនោះនូវជំនួយចាំបាច់នានា ដើម្បីឲ្យបុគ្គលរូបនោះអាចអនុវត្តការទទួលខុសត្រូវរបស់ខ្លួនបាន។

**វិធានទី២៖ តួនាទីរបស់បុគ្គលដែលផ្ដល់ការសម្របសម្រួល**

បុគ្គលដែលផ្ដល់ការសម្របសម្រួលត្រូវជួយភាគីនៃជម្លោះក្នុងជំហរឯករាជ្យ អព្យាក្រឹត្យ និងមិនលំអៀង ដើម្បីដោះស្រាយជម្លោះ។

**វិធានទី៣៖ ក្រមសីលធម៌របស់បុគ្គលដែលផ្ដល់ការសម្របសម្រួល**

បុគ្គលដែលផ្ដល់ការសម្របសម្រួល អាចបន្តអនុវត្តការសម្របសម្រួលក្នុងលក្ខណៈដែលខ្លួនយល់ឃើញថាសមស្រប ដោយគិតគូរដល់កាលៈទេសៈនៃរឿងក្ដី និងបំណងប្រាថ្នាដែលភាគីនៃជម្លោះចង់បាន។

**វិធានទី៤៖ ការរក្សាការសម្ងាត់**

ប្រសិនបើភាគីនៃជម្លោះមិនយល់ព្រមទេ នោះបុគ្គលដែលផ្ដល់ការសម្របសម្រួលនិងភាគីនៃជម្លោះត្រូវរក្សាការសម្ងាត់លើបញ្ហាដែលពាក់ព័ន្ធទៅនឹងដំណើរការនៃការសម្របសម្រួលនេះ ។

**វិធានទី៥៖ ការបញ្ចប់**

១. ការសម្របសម្រួលត្រូវបញ្ចប់៖

- ក. នៅថ្ងៃដែលការជូនដំណឹងជាលាយល័ក្ខអក្សរដោយភាគីនៃជម្លោះ បានផ្ញើទៅក្រុមប្រឹក្សាសម្របសម្រួលអាស៊ានដោយបញ្ជាក់ថាជម្លោះនោះត្រូវបានដោះស្រាយរួចហើយ
- ខ. នៅថ្ងៃដែលមានការជូនដំណឹងជាលាយល័ក្ខអក្សរដោយបុគ្គលផ្ដល់ការសម្របសម្រួល បន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមួយភាគីនៃជម្លោះ ផ្ញើទៅក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយបញ្ជាក់ថាការអនុវត្តការសម្របសម្រួលលែងមានភាពចាំបាច់ ឬត្រូវបានបញ្ជាក់ថាលែងមានលក្ខណៈត្រឹមត្រូវទៀតហើយ

គ. នៅថ្ងៃដែលការជូនដំណឹងជាលាយលក្ខណ៍អក្សរដោយភាគីនៃជម្លោះ ផ្ញើទៅបុគ្គលដែលផ្តល់ការសម្របសម្រួល និងក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយបញ្ជាក់ថាការអនុវត្តការសម្របសម្រួលគួរតែបញ្ចប់ ឬ

ឃ. នៅថ្ងៃដែលការជូនដំណឹងជាលាយលក្ខណ៍អក្សរដោយភាគីម្ខាងនៃជម្លោះ ផ្ញើទៅភាគីម្ខាងទៀតនៃជម្លោះ បុគ្គលដែលផ្តល់ការសម្របសម្រួល និងក្រុមប្រឹក្សាសម្របសម្រួលអាស៊ានដោយបញ្ជាក់ថាការអនុវត្តលើការសម្របសម្រួលគួរតែបញ្ចប់។

----------------------

(សេចក្តីបកប្រែក្រៅផ្លូវការ)

ឧបសម្ព័ន្ធ២

## វិធានស្តីពីសន្ធានកម្ម

### វិធានទី ១ ៖ ការតែងតាំងសន្ធានការី

ត្រូវមានសន្ធានការីមួយរូប។ ភាគីនៃជម្លោះត្រូវយល់ព្រមលើឈ្មោះសន្ធានការី។ ភាគីនៃជម្លោះត្រូវតែងតាំងសន្ធានការី ក្នុងរយៈពេល៤៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងស្តីពីការសម្រេចរបស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន បង្គាប់ឲ្យភាគីនៃជម្លោះដោះស្រាយវិវាទតាមរយៈសន្ធានកម្ម ហើយភាគីនៃជម្លោះនឹងត្រូវជូនដំណឹងជាលាយល័ក្ខអក្សរអំពីការតែងតាំងសន្ធានការីទៅក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ស្របទៅតាមស្ថានភាពជាក់ស្តែង។ ភាគីនៃជម្លោះអាចជ្រើសរើសសន្ធានការី ចេញពីបញ្ជីឈ្មោះដែលរៀបចំ និងរក្សាទុក ដោយអគ្គលេខាធិការអាស៊ាន ស្របតាមវិធាន៥នៃវិធានស្តីពីមជ្ឈត្តវិនិច្ឆ័យ។

### វិធានទី២៖ តួនាទីរបស់សន្ធានការី

សន្ធានការីត្រូវជួយសម្រួលការប្រាស្រ័យទាក់ទង និងការចរចារវាងភាគីនៃជម្លោះ ហើយត្រូវជួយភាគីនៃជម្លោះក្នុងជំហរឯករាជ្យ អព្យាក្រិត្យ និងមិនលំអៀង ដើម្បីដោះស្រាយជម្លោះ។

### វិធានទី៣៖ ការតំណាង និងជំនួយ

ភាគីនៃជម្លោះអាចត្រូវតំណាងឬត្រូវជួយដោយបុគ្គលដែលភាគីនៃជម្លោះជ្រើសរើស។ ឈ្មោះ និងអាសយដ្ឋានរបស់តំណាងទាំងនោះ ត្រូវជូនដំណឹងទៅភាគីជម្លោះម្ខាងទៀត និងសន្ធានការី។ ការជូនដំណឹងបែបនេះគឺដើម្បីបញ្ជាក់ឲ្យច្បាស់ថាតើការតែងតាំងនេះត្រូវបានធ្វើឡើងសម្រាប់គោលបំណងនៃការធ្វើជាតំណាង ឬជាជំនួយ។

### វិធានទី៤៖ ការប្រាស័យទាក់ទងរវាងសន្ធានការី និងភាគីនៃជម្លោះ

សន្ធានការីអាចអញ្ជើញភាគីនៃជម្លោះឲ្យជួបខ្លួន ឬអាចប្រាស័យទាក់ទងជាមួយភាគីនៃជម្លោះ ដោយផ្ទាល់មាត់ ឬជាលាយល័ក្ខអក្សរ។ សន្ធានការីអាចជួបប្រាស័យទាក់ទងជាមួយភាគីនៃជម្លោះរួមគ្នាតែម្តង ឬដាច់ដោយឡែកពីគ្នា។

### វិធានទី៥៖ ការអនុវត្តន៍សន្ធានកម្ម

សន្ធានកម្មត្រូវអនុវត្តក្នុងលក្ខណៈ ដែលមានការយល់ព្រមពីភាគីនៃជម្លោះ។ ប្រសិនបើភាគីនៃ ជម្លោះមិន

មានការព្រមព្រៀងគ្នា សន្ទានការីត្រូវកំណត់ពីរបៀបបទដែលសន្ទានកម្មត្រូវអនុវត្ត ដោយអនុលោមតាម ពិធីសារស្តីពីយន្តការដោះស្រាយជំលោះ និងវិធានទាំងនោះ។

**វិធានទី៦៖ ការផ្សព្វផ្សាយព័ត៌មាន**

នៅពេលដែលសន្ទានការីទទួលព័ត៌មានពិតប្រាកដពាក់ព័ន្ធនឹងជម្លោះ ពីភាគីម្ខាងនៃជម្លោះ សន្ទានការីអាច ផ្តល់ខ្លឹមសារនៃព័ត៌មាននោះទៅភាគីម្ខាងទៀតនៃជម្លោះ ដើម្បីឲ្យភាគីនោះមានឱកាសឆ្លើយតប។ ទោះបី ជាយ៉ាងណាក៏ដោយ នៅពេលដែលភាគីជម្លោះផ្តល់ព័ត៌មានណាមួយទៅឲ្យសន្ទានការី ក្នុងលក្ខខណ្ឌដែល ព័ត៌មាននោះត្រូវរក្សាការសម្ងាត់ សន្ទានការីមិនត្រូវផ្សព្វផ្សាយព័ត៌មាននោះ ទៅភាគីម្ខាងទៀតនៃជម្លោះ ឡើយ។

**វិធានទី៧៖ ការរក្សាការសម្ងាត់**

ប្រសិនបើភាគីនៃជម្លោះមិនមានការព្រមព្រៀងគ្នាទេ សន្ទានការី និងភាគីនៃជម្លោះត្រូវរក្សាការសម្ងាត់រាល់ បញ្ហាទាំងអស់ ដែលទាក់ទងនឹងដំណើរការសន្ទានកម្ម ។

**វិធានទី៨៖ ការបញ្ចប់ដំណើរការសន្ទានកម្ម**

១. ដំណើរការសន្ទានកម្មត្រូវបញ្ចប់៖

ក. នៅថ្ងៃដែលភាគីនៃជម្លោះចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយជម្លោះ

ខ. នៅថ្ងៃដែលការជូនដំណឹងជាលាយល័ក្ខអក្សរធ្វើឡើងដោយសន្ទានការី បន្ទាប់ពីមានការពិគ្រោះ យោបល់ជាមួយភាគីនៃជម្លោះ ផ្ញើទៅកាន់ក្រុមប្រឹក្សាសម្របស្រួលអាស៊ាន ដោយបញ្ជាក់ថា កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការធ្វើសន្ទានកម្ម លែងមានភាពចាំបាច់ ឬត្រូវបានបញ្ជាក់ថា លែងមានភាពត្រឹមត្រូវទៀតហើយ។

គ. នៅថ្ងៃដែលការជូនដំណឹងជាលាយលក្ខអក្សរដោយភាគីនៃជម្លោះ បានផ្ញើទៅសន្ទានការី និងក្រុម ប្រឹក្សាសម្របសម្រួលអាស៊ាន ដែលថាដំណើរការសន្ទានកម្មត្រូវបានបញ្ចប់ ឬ

ឃ. នៅថ្ងៃដែលជូនដំណឹងជាលាយល័ក្ខអក្សរដោយភាគីម្ខាងនៃជម្លោះភាគី ទៅភាគីម្ខាងទៀត នៃជម្លោះ សន្ទានការី (ប្រសិនបើមានការតែងតាំង) និងក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដែលថាដំណើរការសន្ទានកម្មត្រូវបញ្ចប់។

-----------------------

(សេចក្តីបកប្រែក្រៅផ្លូវការ)

ឧបសម្ព័ន្ធ៣

## វិធានស្តីពីការផ្សះផ្សាជម្លោះ

**វិធានទី១៖ ការតែងតាំងអ្នកផ្សះផ្សាជម្លោះ**

១. ត្រូវមានអ្នកផ្សះផ្សាជម្លោះមួយនាក់ ប្រសិនបើភាគីនៃជម្លោះមិនយល់ព្រមឲ្យមានអ្នកផ្សះផ្សាជម្លោះពីរ ឬបីនាក់។ គូភាគីនៃជម្លោះត្រូវតែងតាំងអ្នកផ្សះផ្សាជម្លោះ ក្នុងរយៈពេល៤៥ថ្ងៃ គិតចាប់ពីថ្ងៃដែលគូភាគីនៃជម្លោះបានទទួលការជូនដំណឹងពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយបង្គាប់បញ្ជាឲ្យគូភាគីនៃជម្លោះ ត្រូវដោះស្រាយជម្លោះតាមរយៈការផ្សះផ្សាជម្លោះ ហើយត្រូវជូនដំណឹងទៅក្រុមប្រឹក្សាសម្របសម្រួលអាស៊ានឲ្យស្របទៅតាមស្ថានភាពជាក់ស្តែង។ គូភាគីនៃជម្លោះអាចជ្រើសរើសអ្នកផ្សះផ្សាជម្លោះចេញពីបញ្ជីឈ្មោះអ្នកផ្សះផ្សាជម្លោះដែលរៀបចំ និងរក្សាទុកដោយអគ្គលេខាធិការអាស៊ាន ដោយអនុលោមទៅតាមវិធានទី៥នៃវិធានស្តីពីមជ្ឈត្តកនិច្ឆ័យ។

២. ក្នុងករណីដែលមានអ្នកផ្សះផ្សាជម្លោះលើសពីមួយនាក់ យោងតាមវិធានទូទៅ អ្នកផ្សះផ្សាជម្លោះទាំងនេះគួរបំពេញការងាររួមគ្នា។ សេចក្តីសម្អាងក្នុងវិធានទាំងនេះ សម្រាប់អ្នកផ្សះផ្សាជម្លោះត្រូវបកស្រាយ ដើម្បីបន្ថែមអ្នកផ្សះផ្សាជម្លោះនានា ក្នុងករណីដែលគូភាគីនៃជម្លោះបានយល់ព្រមថា ត្រូវមានអ្នកផ្សះផ្សាជម្លោះពីរ ឬបីនាក់។

៣. (ក) ក្នុងដំណើរការនៃការផ្សះផ្សាជម្លោះ ក្រោមសមត្ថកិច្ចរបស់អ្នកផ្សះផ្សាជម្លោះមួយនាក់ ភាគីនៃជម្លោះត្រូវខិតខំសម្រេចឲ្យបាននូវកិច្ចព្រមព្រៀងក្នុងការកំណត់យកអ្នកផ្សះផ្សាជម្លោះតែម្នាក់នោះ។

(ខ) ក្នុងដំណើរការនៃការផ្សះផ្សាជម្លោះ ក្រោមសមត្ថកិច្ចរបស់អ្នកផ្សះផ្សាជម្លោះពីរនាក់ ភាគីនីមួយៗនៃជម្លោះត្រូវតែងតាំងអ្នកផ្សះផ្សាជម្លោះមួយនាក់។

(គ) ក្នុងដំណើរការនៃការផ្សះផ្សាជម្លោះ ក្រោមសមត្ថកិច្ចរបស់អ្នកផ្សះផ្សាជម្លោះបីនាក់ ភាគីនីមួយៗនៃជម្លោះ ត្រូវតែងតាំងអ្នកផ្សះផ្សាជម្លោះមួយនាក់។ គូភាគីនៃជម្លោះត្រូវខិតខំសម្រេចឲ្យបាននូវកិច្ចព្រមព្រៀងក្នុងការកំណត់យកអ្នកផ្សះផ្សាជម្លោះទីបី។

**វិធានទី២៖ ការដាក់សេចក្តីសម្អាងហេតុទៅអ្នកផ្សះផ្សាជម្លោះ**

១. ក្រោយពីបានទទួលការតែងតាំង អ្នកផ្សះផ្សាជម្លោះត្រូវស្នើសុំពីភាគីនីមួយៗនៃជម្លោះ ឲ្យដាក់ជូនខ្លួននូវសេចក្តីសម្អាងហេតុសង្ខេប ដែលរៀបរាប់បញ្ជាក់អំពីលក្ខណៈទូទៅនៃជម្លោះ និងចំណុចវិវាទ។ គូភាគីនីមួយៗនៃជម្លោះ ត្រូវផ្ញើសេចក្តីសម្អាងហេតុនេះមួយច្បាប់ ជូនភាគីម្ខាងទៀត។

២. អ្នកផ្សះផ្សាជម្លោះអាចស្នើសុំទៅភាគីនៃជម្លោះ ឲ្យដាក់ជូនខ្លួននូវសេចក្តីសម្អាងហេតុជាលាយលក្ខណ៍អក្សរដែលបញ្ជាក់អំពីគោលជំហរ ហើយនិងអង្គហេតុ និងសារតានៃជម្លោះ ដោយភ្ជាប់មកជាមួយនូវឯកសារបំពេញបន្ថែម និងភស្តុតាងផ្សេងទៀតដែលមានលក្ខណៈសមស្រប។ ភាគីនៃជម្លោះត្រូវផ្ញើសេចក្តីសម្អាងហេតុរបស់ខ្លួនមួយច្បាប់ទៅភាគីម្ខាងទៀត។

៣. ក្នុងដំណាក់កាលនីមួយៗនៃដំណើរការផ្សះផ្សាជម្លោះ អ្នកផ្សះផ្សាជម្លោះអាចស្នើសុំភាគីណាមួយនៃជម្លោះ ឲ្យដាក់ជូនខ្លួននូវព័ត៌មានបន្ថែម ក្នុងករណីដែលអ្នកផ្សះផ្សាជម្លោះគិតថាសមស្រប។

**វិធានទី៣៖ ការតំណាង និងជំនួយ**

ភាគីនៃជម្លោះអាចត្រូវបានតំណាង ឬត្រូវជួយដោយបុគ្គលដែលភាគីនៃជម្លោះជ្រើសរើស។ ភាគីនៃជម្លោះត្រូវជូនដំណឹងដល់ភាគីម្ខាងទៀត និងអ្នកផ្សះផ្សាជម្លោះអំពីឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលរូបនោះ។ ការជូនដំណឹងបែបនេះត្រូវបញ្ជាក់ឲ្យច្បាស់ថាតើការតែងតាំងបុគ្គលរូបនេះ ធ្វើឡើងក្នុងគោលបំណងជាការតំណាង ឬជាជំនួយ។

**វិធានទី៤៖ តួនាទីរបស់អ្នកផ្សះផ្សាជម្លោះ**

១. អ្នកផ្សះផ្សាជម្លោះត្រូវជួយភាគីនៃជម្លោះ ក្នុងការដោះស្រាយជម្លោះក្នុងជំហរឯករាជ្យ អព្យាក្រឹត្យ និងមិនលំអៀង។

២. អ្នកផ្សះផ្សាជម្លោះត្រូវគោរពទៅតាមគោលការណ៍សត្យានុម័ត ភាពត្រឹមត្រូវ និងយុត្តិធម៌ ដោយពិចារណាទៅលើសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៃជម្លោះ និងកាលៈទេសៈ ដែលពាក់ព័ន្ធនឹងជម្លោះ ក្នុងនោះរួមមានទាំងការអនុវត្តន៍ដែលមានកន្លងមករវាងភាគីនៃជម្លោះផង។

៣. ក្នុងដំណាក់កាលណាមួយនៃដំណើរការផ្សះផ្សាជម្លោះ អ្នកផ្សះផ្សាជម្លោះអាចលើកសំណើសម្រាប់ដំណោះស្រាយជម្លោះបាន។ សំណើបែបនោះពុំចាំបាច់ធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ហើយក៏ពុំចាំបាច់ភ្ជាប់ជាមួយនិងសេចក្តីសម្អាងហេតុទេ។

**វិធានទី៥៖ ការប្រាស្រ័យទាក់ទងរវាងអ្នកផ្សះផ្សាជម្លោះ និងភាគីនៃជម្លោះ**

អ្នកផ្សះផ្សាជម្លោះអាចអញ្ជើញភាគីនៃជម្លោះឲ្យជួបប្រជុំជាមួយខ្លួន ឬអាចទាក់ទងជាមួយភាគីនៃជម្លោះដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ អ្នកផ្សះផ្សាជម្លោះអាចទាក់ទងជាមួយភាគីនៃជម្លោះទាំងពីរព្រមគ្នាក៏បាន ឬជាមួយភាគីម្ខាងម្តងៗដោយឡែកពីគ្នាក៏បាន។

**វិធានទី៦៖ ការអនុវត្តន៍ការផ្សះផ្សាជម្លោះ**

អ្នកផ្សះផ្សាជម្លោះអាចអនុវត្តដំណើរការផ្សះផ្សាជម្លោះតាមលក្ខណៈដែលខ្លួនគិតថាសមស្រប ដោយពិចារណាទៅលើកាលៈទេសៈនៃករណីជម្លោះ បំណងរបស់ភាគីនៃជម្លោះ ក្នុងនោះរួមទាំងសំណើណាមួយដែលភាគីនៃជម្លោះស្នើឲ្យអ្នកផ្សះផ្សាជម្លោះស្តាប់សេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងតម្រូវការពិសេសណាមួយសម្រាប់ការដោះស្រាយជម្លោះឲ្យបានឆាប់រហ័ស ព្រមទាំងបទប្បញ្ញត្តិផ្សេងៗដែលមានចែងនៅក្នុងពិធីសារ និងវិធានទាំងនេះ។

**វិធានទី៧ ៖ ការផ្សព្វផ្សាយព័ត៌មាន**

នៅពេលដែលអ្នកផ្សះផ្សាជម្លោះទទួលបានព័ត៌មានពិតប្រាកដពាក់ព័ន្ធនឹងជម្លោះពីភាគីនៃជម្លោះ អ្នកផ្សះផ្សាជម្លោះអាចបញ្ជូនខ្លឹមសារនៃព័ត៌មាននេះទៅភាគីនៃជម្លោះម្ខាងទៀត ដើម្បីឱ្យភាគីនោះអាចមានឱកាសឆ្លើយតប។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលភាគីនៃជម្លោះជូនព័ត៌មានក្នុងលក្ខខណ្ឌជាក់លាក់ដែលត្រូវរក្សាការសម្ងាត់ទៅអ្នកផ្សះផ្សាជម្លោះ អ្នកផ្សះផ្សានោះមិនត្រូវបញ្ជូនព័ត៌មាននោះទៅភាគីនៃជម្លោះម្ខាងទៀតទេ។

**វិធានទី៨ ៖ កិច្ចសហប្រតិបត្តិការរបស់ភាគីនៃជម្លោះជាមួយអ្នកផ្សះផ្សាជម្លោះ**

ភាគីនៃជម្លោះត្រូវធ្វើកិច្ចសហប្រតិបត្តិការប្រកបដោយភាពស្មោះត្រង់ជាមួយអ្នកផ្សះផ្សាជម្លោះ ជាពិសេស ត្រូវខិតខំប្រតិបត្តិតាមសំណើរបស់អ្នកផ្សះផ្សាជម្លោះ ដើម្បីដាក់សំណើជាលាយលក្ខណ៍អក្សរ ផ្តល់ជាភស្តុតាង និងចូលរួមកិច្ចប្រជុំនានា។

**វិធានទី៩ ៖ សំណើរបស់ភាគីនៃជម្លោះសម្រាប់ដោះស្រាយជម្លោះ**

ភាគីនៃជម្លោះអាចដាក់សំណើទៅអ្នកផ្សះផ្សាជម្លោះសម្រាប់ការដោះស្រាយជម្លោះ តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន ឬតាមការអញ្ជើញរបស់អ្នកផ្សះផ្សាជម្លោះ។

**វិធានទី១០ ៖ កិច្ចព្រមព្រៀងដំណោះស្រាយ**

១. នៅពេលដែលអ្នកផ្សះផ្សាជម្លោះយល់ថាមានចំណុចសំខាន់ៗនៃដំណោះស្រាយ ដែលមានលក្ខណៈអាចទទួលយកបានចំពោះភាគីនៃជម្លោះ អ្នកផ្សះផ្សាជម្លោះត្រូវរៀបចំលក្ខខណ្ឌនៃដំណោះស្រាយសមស្រប និងដាក់លក្ខខណ្ឌនោះជូនភាគីនៃជម្លោះ ដើម្បីពិនិត្យ។ បន្ទាប់ពីបានទទួលកំណត់សម្គាល់របស់ភាគីនៃជម្លោះ អ្នកផ្សះផ្សាអាចរៀបចំជាថ្មីនូវលក្ខខណ្ឌនៃដំណោះស្រាយសមស្រប ដោយយោងតាមកំណត់សម្គាល់នោះ។

២. ប្រសិនបើភាគីនៃជម្លោះសម្រេចបាននូវកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយជម្លោះ ភាគីនៃជម្លោះត្រូវរៀបចំ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងដំណោះស្រាយជម្លោះជាលាយលក្ខណ៍អក្សរ។ ប្រសិនបើមានការស្នើពីភាគីនៃជម្លោះ អ្នកផ្សះផ្សាជម្លោះត្រូវរៀបចំ ឬជួយភាគីនៃជម្លោះក្នុងការរៀបចំកិច្ចព្រមព្រៀងដោះស្រាយជម្លោះនេះ។

**វិធានទី១១ ៖ ការរក្សាការសម្ងាត់**

ប្រសិនបើភាគីនៃជម្លោះមិនយល់ព្រម នោះអ្នកផ្សះផ្សាជម្លោះ និងភាគីនៃជម្លោះត្រូវរក្សាការសម្ងាត់នូវរាល់រឿងក្តីដែលពាក់ព័ន្ធនឹងដំណើរការនៃការផ្សះផ្សា។

**វិធានទី១២៖ ការបញ្ចប់ដំណើរការផ្សះផ្សាជម្លោះ**

ដំណើរការផ្សះផ្សាជម្លោះត្រូវបញ្ចប់៖

(ក) នៅថ្ងៃដែលគូភាគីនៃជម្លោះចុះហត្ថលេខាលើកិច្ចព្រមព្រៀងដំណោះស្រាយជម្លោះ

(ខ) នៅថ្ងៃដែលការជូនដំណឹងជាលាយលក្ខអក្សរធ្វើឡើងដោយអ្នកផ្សះផ្សាជម្លោះ ផ្ញើទៅកាន់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយភាគីនៃជម្លោះ ដោយបញ្ជាក់ថាកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការផ្សះផ្សាជម្លោះ ពុំមានភាពចាំបាច់ ឬត្រូវបានបញ្ជាក់ថាត្រឹមត្រូវហើយ។

(គ) នៅថ្ងៃដែលមានការជូនដំណឹងជាលាយលក្ខអក្សរពីសំណាក់ភាគីនៃជម្លោះ ទៅកាន់អ្នកផ្សះផ្សាជម្លោះ និងក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយបញ្ជាក់ថាដំណើរការផ្សះផ្សាជម្លោះត្រូវបានបញ្ចប់ហើយ។ ឬ

(ឃ) នៅថ្ងៃដែលការជូនដំណឹងជាលាយលក្ខណ៍អក្សរពីសំណាក់ភាគីនៃជម្លោះ ទៅភាគីនៃជម្លោះម្ខាងទៀត អ្នកផ្សះផ្សាជម្លោះ (ក្នុងករណីដែលមានការតែងតាំង) និងក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយបញ្ជាក់ថាដំណើរការផ្សះផ្សាជម្លោះត្រូវបានបញ្ចប់ហើយ។

**វិធានទី១៣៖ តួនាទីរបស់អ្នកផ្សះផ្សាជម្លោះនៅក្នុងដំណើរការផ្សេងៗទៀត**

ភាគីនៃជម្លោះ និងអ្នកផ្សះផ្សាជម្លោះ សម្រេចថា ប្រសិនបើភាគីនៃជម្លោះមិនយល់ព្រមនោះទេ អ្នកផ្សះផ្សាជម្លោះត្រូវបំពេញតួនាទីជាមជ្ឈត្តករ ឬជាអ្នកតំណាង ឬក៏ជាទីប្រឹក្សារបស់ភាគីនៃជម្លោះ ក្នុងដំណើរការនៃមជ្ឈត្តវិនិច្ឆ័យ ឬដំណើរការតាម

ផ្លូវតុលាការ តាមលក្ខណៈនៃជម្លោះ ដែលជាកម្មវត្ថុនៃដំណើរការផ្សះផ្សាជម្លោះនេះ។ ភាគីនៃជម្លោះសម្រេចផងដែរថាពួកគេមិនត្រូវឲ្យអ្នកផ្សះផ្សាបំពេញតួនាទីជាសាក្សី ក្នុងដំណើរការណាមួយឡើយ។

**វិធានទី១៤៖ ការអាចដាក់ភស្តុតាងចូលទៅក្នុងដំណើរការផ្សេងៗទៀតបាន**

ភាគីនៃជម្លោះសម្រេចថាមិនពឹងផ្អែកទៅលើ ឬបង្ហាញភស្តុតាង ក្នុងដំណើរការមជ្ឈត្តវិនិច្ឆ័យ ឬដំណើរការតាមផ្លូវតុលាការ ទោះបីដំណើរការទាំងនោះជាប់ទាក់ទង ឬមិនជាប់ទាក់ទងទៅនឹងជម្លោះដែលជាកម្មវត្ថុនៃដំណើរការផ្សះផ្សាជម្លោះនេះក៏ដោយក្តី ចំពោះ៖

(ក) ទស្សនៈដែលសម្តែងឡើង ឬសំណើ ដែលលើកឡើងដោយភាគីម្ខាងទៀតនៃជម្លោះ ដោយគោរពទៅតាមដំណោះស្រាយជម្លោះដែលអាចធ្វើទៅបាន

(ខ) ការដាក់ភស្តុតាងដែលធ្វើឡើងដោយភាគីម្ខាងទៀតនៃជម្លោះ ក្នុងកំឡុងពេលនៃដំណើរការផ្សះផ្សាជម្លោះ

(គ) សំណើដែលធ្វើឡើងដោយអ្នកផ្សះផ្សាជម្លោះ

(ឃ) អង្គហេតុដែលភាគីម្ខាងទៀតនៃជម្លោះបានបង្ហាញនូវឆន្ទៈរបស់ខ្លួន ដើម្បីទទួលយកសំណើសម្រាប់ដោះស្រាយជម្លោះដែលធ្វើឡើងដោយអ្នកផ្សះផ្សាជម្លោះ។

-------------------

(សេចក្ដីបកប្រែក្រៅផ្លូវការ)

## ឧបសម្ព័ន្ធ៤

# វិធានស្ដីពីមជ្ឈត្តនិច្ឆ័យ

### វិធានទី១៖ ការតែងតាំងមជ្ឈត្តករ

១- មជ្ឈត្តនិច្ឆ័យត្រូវមានមជ្ឈត្តករ ៣ នាក់។

២- ភាគីនៃជម្លោះត្រូវតែងតាំងមជ្ឈត្តករមួយនាក់ ហើយត្រូវជូនដំណឹងទៅភាគីម្ខាងទៀតនៃជម្លោះក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួលការឆ្លើយតបពីភាគីឆ្លើយតប ដែលបានយល់ព្រមតាមសំណើឲ្យមានមជ្ឈត្តនិច្ឆ័យ ឬក្នុងរយៈពេល៤៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានការជូនដំណឹងពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដែលបានតម្រូវឲ្យភាគីនៃជម្លោះ ដោះស្រាយជម្លោះតាមរយៈមជ្ឈត្តនិច្ឆ័យ។

៣- ប្រសិនបើភាគីនៃជម្លោះមិនបានតែងតាំងមជ្ឈត្តករ ទៅតាមថិរវេលាដូចមានចែងក្នុងវាក្យខណ្ឌទី២នៃវិធាននេះទេ ក្នុងរយៈពេល១៥ថ្ងៃ ភាគីម្ខាងទៀតនៃជម្លោះ ដែលបានតែងតាំងមជ្ឈត្តកររបស់ខ្លួនរួចហើយ អាចស្នើអគ្គលេខាធិការអាស៊ានតែងតាំងមជ្ឈត្តករទី២បាន។ ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសំណើ និងដោយបានពិគ្រោះយោបល់ជាមួយភាគីនៃជម្លោះ ដែលមិនបានតែងតាំងមជ្ឈត្តករ អគ្គលេខាធិការអាស៊ានត្រូវតែងតាំងមជ្ឈត្តករទី២ និងជូនព័ត៌មានទៅភាគីនៃជម្លោះពាក់ព័ន្ធនឹងការតែងតាំងនោះ។ ក្នុងករណីនេះ មជ្ឈត្តករនឹងត្រូវរើសចេញពីបញ្ជី ដែលត្រូវរក្សាទុក ដោយអនុលោមតាមវិធានទី៥។

៤-ក. ភាគីនៃជម្លោះត្រូវយល់ព្រមចំពោះការតែងតាំងមជ្ឈត្តករទី៣ ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីថ្ងៃទទួលបានការជូនដំណឹងនៃការតែងតាំងមជ្ឈត្តករទី២ និងត្រូវជូនដំណឹងជាបន្ទាន់ទៅអគ្គលេខាធិការអាស៊ានអំពីការតែងតាំងនេះ។

ខ. ប្រសិនបើភាគីនៃជម្លោះមិនបានយល់ព្រមលើការតែងតាំងមជ្ឈត្តករទី៣ទេ ភាគីណាមួយនៃជម្លោះអាចស្នើឲ្យប្រធានក្រុមប្រឹក្សាសម្របសម្រួលអាស៊ានតែងតាំងមជ្ឈត្តករទី៣បាន។ ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសំណើបែបនេះ ប្រធានក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវតែងតាំងមជ្ឈត្តករទី៣ តាមការផ្ដល់អនុសាសន៍ពីអគ្គលេខាធិការអាស៊ាន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ាន និងត្រូវជូនដំណឹងជាបន្ទាន់ទៅអគ្គលេខាធិការអាស៊ាន និងភាគីជម្លោះពាក់ព័ន្ធអំពីការតែងតាំង។

គ. មជ្ឈត្តករទី៣ ត្រូវធ្វើជាប្រធាននៃមជ្ឈត្តនិច្ឆ័យនេះ។

ឃ. ក្នុងការតែងតាំងមជ្ឈត្តករ ស្របតាមវាក្យខណ្ឌទី៤(ខ) នៃវិធាននេះ ប្រធានក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវតែងតាំងពលរដ្ឋអាស៊ានមួយរូបដែលមានឈ្មោះក្នុងបញ្ជីដែលត្រូវត្រូវរក្សាទុក ដោយអនុលោមតាមវិធានទី៥ លុះត្រាតែបុគ្គលរូបនោះអះអាងថាមានកាលៈទេសៈជាអញ្ញត្រកម្ម។

ង. ប្រសិនបើប្រធានក្រុមប្រឹក្សាសម្របសម្រួលអាស៊ានមានសញ្ជាតិរបស់រដ្ឋជាភាគីនៃជម្លោះ ការតែងតាំងមជ្ឈត្តករទី៣ត្រូវធ្វើឡើងដោយប្រធានថ្មីនៃក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដែលមិនមានសញ្ជាតិរដ្ឋជាភាគីនៃជម្លោះ។

៥- កាលបរិច្ឆេទបង្កើតមជ្ឈត្តវិនិច្ឆ័យ ត្រូវទៅនឹងកាលបរិច្ឆេទដែលមជ្ឈត្តករទី៣ ត្រូវបានតែងតាំង។ អគ្គលេខាធិការអាស៊ាន ត្រូវជូនដំណឹងភ្លាមទៅរដ្ឋសមាជិកទាំងអស់ អំពីកាលបរិច្ឆេទនេះ។

៦- មជ្ឈត្តករជំនួសត្រូវតែងតាំងឡើង តាមរបៀបដូចគ្នាទៅនឹងការតែងតាំងមជ្ឈត្តករដែលត្រូវបានតែងតាំងពីដំបូង ហើយត្រូវមានអំណាច និងភារកិច្ចដូចគ្នានឹងមជ្ឈតករដែលត្រូវបានតែងតាំងពីដំបូងដែរ។ ការងាររបស់មជ្ឈត្តវិនិច្ឆ័យ នឹងត្រូវផ្អាករហូតដល់មានការតែងតាំងមជ្ឈត្តករជំនួស។

## វិធានទី២៖ ការចោទសួរអំពីសាវតារបស់មជ្ឈត្តករ

១- មជ្ឈត្តករដែលនឹងត្រូវតែងតាំង ត្រូវបង្ហាញដល់អ្នកដែលបានទាក់ទងខ្លួន ពាក់ព័ន្ធនឹងការតែងតាំងអាស្រ័យដោយសាវតារបស់មជ្ឈត្តកររូបនោះ អាចនាំឲ្យមានមន្ទិលសង្ស័យអំពីភាពមិនលម្អៀង និងឯករាជ្យភាពរបស់ខ្លួន។ មជ្ឈត្តករដែលត្រូវបានតែងតាំងរួចហើយ ត្រូវបង្ហាញព័ត៌មានទាំងនេះជូនទៅភាគីនៃជម្លោះ ប្រសិនបើមជ្ឈត្តករដែលត្រូវបានតែងតាំងនោះមិនបានជូនព័ត៌មានទៅភាគីនៃជម្លោះអំពីសាវតារបស់ខ្លួន។

២- មជ្ឈត្តករអាចត្រូវសាកសួរពីសំណាក់ភាគី អំពីសាវតារបស់ខ្លួន ប្រសិនបើសាវតានេះអាចធ្វើឲ្យមានមន្ទិលសង្ស័យចំពោះភាពមិនលម្អៀង និងឯករាជ្យភាពរបស់មជ្ឈត្តកររូបនោះ។

៣- ភាគីណាមួយនៃជម្លោះអាចធ្វើការចោទសួរមជ្ឈត្តករដែលខ្លួនបានតែងតាំង ចំពោះតែក្នុងហេតុផលនានាដែលខ្លួនបានដឹងក្រោយពេលតែងតាំងតែប៉ុណ្ណោះ។

៤- ភាគីនៃជម្លោះដែលមានបំណងសាកសួរមជ្ឈត្តករ ត្រូវជូនដំណឹងអំពីការសាកសួរនេះ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលទទួលបានដំណឹងពីការតែងតាំងមជ្ឈត្តករដែលត្រូវសាកសួររូបនោះ ឬក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីភាគីនៃជម្លោះបានដឹងពីកាលៈទេសៈដូចមានចែងក្នុងវាក្យខណ្ឌទី១ ដល់វាក្យខណ្ឌទី៣នៃវិធាននេះ។

៥- ការចង់សាកសួរ ត្រូវមានការជូនដំណឹងទៅភាគីនៃជម្លោះ មជ្ឈត្តករដែលនឹងត្រូវគេសាកសួរ និងសមាជិកដទៃទៀតនៃមជ្ឈត្តវិនិច្ឆ័យ។ ការជូនដំណឹងត្រូវបញ្ជាក់ពីហេតុផលនៃការសាកសួរនោះ។

៦- នៅពេលមជ្ឈត្តករត្រូវបានសាកសួរដោយភាគីជម្លោះរួចហើយ ភាគីម្ខាងទៀតនៃជម្លោះអាចយល់ស្របទៅនឹងការសាកសួរនោះ។ បន្ទាប់ពីការសាកសួរ មជ្ឈត្តកររូបនោះអាចដកខ្លួនចេញពីមជ្ឈត្តវិនិច្ឆ័យបាន។ ក្នុងករណីណាក៏ដោយ ការសាកសួរមានន័យបញ្ជាក់អំពីការទទួលយកសុពលភាពនៃមូលដ្ឋានអំពីការសាកសួរ។ ក្នុងករណីទាំងពីរ នីតិវិធីដែលមានចែងក្នុងវិធានទី១នឹងត្រូវប្រើពេញលេញសម្រាប់ការតែង

តាំងមជ្ឈត្តករជំនួស សូម្បីតែក្នុងអំឡុងពេលដំណើរការនៃការតែងតាំងមជ្ឈត្តករដែលត្រូវសាកសួរក៏ដោយក្តី ភាគីនៃជម្លោះមិនបានប្រើសិទ្ធិក្នុងការតែងតាំង ឬចូលរួមក្នុងការតែងតាំងនោះបានទេ។

៧- ប្រសិនបើភាគីជម្លោះមិនយល់ព្រមទៅនឹងការសាកសួរ ហើយមជ្ឈត្តករដែលត្រូវសាកសួរពុំបានដកខ្លួនពីមជ្ឈត្តវិនិច្ឆ័យទេនោះ ការសម្រេចចិត្តក្នុងការសាកសួរ ត្រូវធ្វើឡើងដោយ៖

ក. អគ្គលេខាធិការអាស៊ាន ដោយពិគ្រោះយោបល់ជាមួយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ាន នៅចំពោះការតែងតាំងត្រូវបានធ្វើឡើងដោយអនុលោមតាមវាក្យខណ្ឌទី(២) និងទី(៣) នៃវិធានទី១ ឬ

ខ. ប្រធានក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដោយមានអនុសាសន៍ពីអគ្គលេខាធិការអាស៊ាន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍អាស៊ាន ចំពោះការតែងតាំងត្រូវបានធ្វើឡើងដោយអនុលោមតាមវាក្យខណ្ឌទី៤ នៃវិធានទី១។

៨- ប្រសិនបើមានការសាកសួរជាបន្ត មជ្ឈត្តករជំនួសត្រូវតែងតាំងឡើង ដោយស្របតាមនីតិវិធីនៃការតែងតាំងមជ្ឈត្តករ ដូចមានចែងក្នុងវិធានទី១។

**វិធានទី៣៖ ការជំនួសមជ្ឈត្តករ**

១- ក្នុងករណីមជ្ឈត្តករទទួលមរណភាព ឬលាលែងពីតំណែងពេលក្នុងអំឡុងពេលដំណើរការរបស់មជ្ឈត្តវិនិច្ឆ័យមជ្ឈត្តករជំនួសនឹងត្រូវតែងតាំងឡើង ដោយអនុលោមតាមនីតិវិធីក្នុងវិធានទី១ ដែលអនុវត្តចំពោះការតែងតាំងមជ្ឈត្តករដែលត្រូវជំនួស។ ការលាលែងរបស់មជ្ឈត្តករ ត្រូវជម្រាបជូនមជ្ឈត្តវិនិច្ឆ័យ និងជូនដំណឹងទៅអគ្គលេខាធិការអាស៊ាន និងភាគីនៃជម្លោះ ហើយការលាលែងនេះត្រូវកំណត់ដោយមជ្ឈត្តវិនិច្ឆ័យថាមានហេតុផលគ្រប់គ្រាន់ ដែលអាចទទួលយកបានសម្រាប់ការលាលែងនេះ។ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យកំណត់ទទួលយកការលាលែងនេះ ការលាលែងអាចមានប្រសិទ្ធភាព នៅថ្ងៃដែលមជ្ឈត្តវិនិច្ឆ័យបានកំណត់ទទួលយក។ ចំពោះករណីដែលមជ្ឈត្តវិនិច្ឆ័យមិនទទួលយកការលាលែងរបស់មជ្ឈត្តករ ប៉ុន្តែមជ្ឈត្តកររូបនោះមិនបានចូលរួមក្នុងដំណើរការមជ្ឈត្តវិនិច្ឆ័យ វាក្យខណ្ឌទី៣ នៃវិធាននេះត្រូវយកមកអនុវត្ត។

២- ក្នុងករណីដែលមជ្ឈត្តករមិនបានបំពេញ ឬក្នុងករណីគ្មានលទ្ធភាពបំពេញមុខងាររបស់ខ្លួន តាមអង្គហេតុ ឬតាមអង្គច្បាប់ នីតិវិធីនៃការសាកសួរ និងការដាក់ជំនួសមជ្ឈត្តករថ្មី ដូចមានចែងក្នុងវិធានទី២ និងវាក្យខណ្ឌទី១នៃវិធាននេះ នឹងត្រូវយកមកអនុវត្ត ដោយអនុលោមតាមវាក្យខណ្ឌទី៣ នៃវិធាននេះ។

៣- ប្រសិនបើមជ្ឈត្តករម្នាក់ មិនបានចូលរួមក្នុងដំណើរការនៃមជ្ឈត្តវិនិច្ឆ័យ លើកលែងតែភាគីនៃជម្លោះមិនបានឯកភាព មជ្ឈត្តករដទៃទៀតមានអំណាចទៅតាមឆន្ទានុសិទ្ធរបស់ខ្លួនដើម្បីបន្តការវិនិច្ឆ័យសេចក្តីបង្គាប់បញ្ជា ឬចេញសេចក្តីសម្រេច បើទោះបីជាមិនមានការចូលរួមពីសំណាក់មជ្ឈត្តករមួយនាក់ក៏ដោយ។ ចំពោះការកំណត់ថាតើត្រូវបន្តការវិនិច្ឆ័យសេចក្តី ធ្វើសេចក្តីសម្រេច ឬចេញសេចក្តីសម្រេច

ណាមួយ ក្នុងករណីដែលគ្មានវត្តមានរបស់មជ្ឈត្តករមួយនាក់នោះ មជ្ឈត្តករដទៃទៀតនឹងត្រូវទទួលបន្ទុកការវិនិច្ឆ័យសេចក្តី នៅពេលមានហេតុផលបញ្ជាក់ពីការមិនអាចចូលរួមបានរបស់មជ្ឈត្តកររូបនោះ (ប្រសិនបើមាន) និងបញ្ហាណាមួយផ្សេងទៀត ដែលមជ្ឈត្តករផ្សេងទៀតយល់ថាសមស្របទៅតាមកាលៈទេសៈនៃរឿងក្តីនោះ។ ក្នុងករណីមជ្ឈត្តករដទៃទៀតកំណត់ថាមិនបន្តការវិនិច្ឆ័យសេចក្តី ដោយមិនមានការចូលរួមពីសំណាក់មជ្ឈត្តករ ដែលមិនបានចូលរួមក្នុងដំណើរការនៃមជ្ឈត្តវិនិច្ឆ័យនោះ មជ្ឈត្តវិនិច្ឆ័យនឹងត្រូវប្រកាសពីភាពទំនេរ ហើយមជ្ឈត្តករជំនួសនឹងត្រូវចាត់តាំងស្របតាមនីតិវិធី ដូចដែលមានចែងចំពោះការចាត់តាំងមជ្ឈត្តករ ក្នុងវិធានទី១។

## វិធានទី៤៖ ការធ្វើសវនាការជាថ្មីឡើងវិញ

ប្រសិនបើយោងតាមវិធានទី២ ឬទី៣ ដែលប្រធានមជ្ឈត្តវិនិច្ឆ័យត្រូវបានជំនួស រាល់សវនាការដែលត្រូវបានធ្វើឡើងកន្លងមកទាំងអស់ នឹងត្រូវធ្វើសារជាថ្មីម្តងទៀត។ ប្រសិនបើមជ្ឈត្តករណាមួយត្រូវបានជំនួស នោះសវនាការដែលបានធ្វើកន្លងមក អាចនឹងត្រូវធ្វើសារជាថ្មី តាមឆន្ទានុសិទ្ធិរបស់មជ្ឈត្តវិនិច្ឆ័យ។

## វិធានទី៥៖ បញ្ជីឈ្មោះបុគ្គលដែលអាចធ្វើជាមជ្ឈត្តករ

១- បញ្ជីឈ្មោះបុគ្គលដែលមានលក្ខណសម្បត្តិ ស្របតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ និង៣ នៃមាត្រាទី១១ ស្តីពីការតែងតាំងមជ្ឈត្តករនៃពិធីសារនេះ ត្រូវរៀបចំនិងរក្សាទុកដោយលេខាធិការដ្ឋានអាស៊ាន ដែលនឹងមានភារៈធ្វើបច្ចុប្បន្នភាពជូនបណ្តារដ្ឋសមាជិកនីមួយៗ អំពីការផ្លាស់ប្តូរណាមួយនៃបញ្ជីឈ្មោះនេះ។ រដ្ឋសមាជិកនីមួយៗ មានសិទ្ធិធ្វើការតែងតាំងបុគ្គលចំនួន១០រូប។

២- រដ្ឋសមាជិកមួយ អាចដកឈ្មោះបុគ្គលដែលខ្លួនបានតែងតាំងចេញពីបញ្ជីបាន។ ការដកចេញពីបញ្ជីនៃការតែងតាំងបែបនេះ នឹងមិនប៉ះពាល់ដល់បុគ្គលដែលបានតែងតាំងរួចហើយនោះទេ។

៣- ប្រសិនបើនៅពេលណាមួយ បុគ្គលត្រូវបានតែងតាំងដោយរដ្ឋសមាជិកមួយនៅក្នុងបញ្ជី មានចំនួនតិចជាង១០នាក់ រដ្ឋជាសមាជិកនោះត្រូវមានសិទ្ធិធ្វើការតែងតាំងបន្ថែមទៀតតាមការចាំបាច់។

## វិធានទី៦៖ នីតិវិធីសម្រាប់ករណីពាក់ព័ន្ធនឹងរដ្ឋជាសមាជិកលើសពីពីរ

១- នៅពេលមានរដ្ឋសមាជិកលើសពីពីរពាក់ព័ន្ធនឹងជម្លោះលើបញ្ហាតែមួយ នោះមជ្ឈត្តវិនិច្ឆ័យមួយអាចនឹងត្រូវបង្កើតឡើងដើម្បីពិនិត្យលើបណ្តឹង ស្របទៅតាមកិច្ចព្រមព្រៀងចំពោះកិច្ចដែលត្រូវបានធ្វើឡើងដោយរដ្ឋសមាជិកដែលពាក់ព័ន្ធនឹងជម្លោះនេះ។ ក្នុងករណីនេះ នីតិវិធីដូចដែលបានចែងក្នុងវិធានទាំងនេះ ត្រូវយកមកអនុវត្តឲ្យបានពេញលេញតាមតែអាចធ្វើទៅបាន។

២- មជ្ឈត្តវិនិច្ឆ័យតែមួយនឹងរៀបចំការពិនិត្យរបស់ខ្លួន ហើយចេញសេចក្តីសម្រេច ក្នុងលក្ខណៈដែលមិនធ្វើឲ្យថមថយនូវសិទ្ធិរបស់ភាគីនៃជម្លោះ ក្នុងការប្រើប្រាស់មជ្ឈត្តវិនិច្ឆ័យដោយឡែក ដើម្បីពិនិត្យលើបណ្តឹងរបស់ខ្លួនឡើយ។

**វិធានទី៧៖ ភាគីទីបី**

ភាគីនៃជំលោះអាចយល់ព្រមផ្តល់សិទ្ធិបន្ថែមចំពោះសិទ្ធិទាំងឡាយណា ដែលមានចែងនៅក្នុងមាត្រា១៣នៃពិធីសារនេះ ទៅឲ្យភាគីទី៣ ចំពោះការចូលរួមក្នុងដំណើរការនៃមជ្ឈត្តវិនិច្ឆ័យ។ ក្នុងការផ្តល់សិទ្ធិបន្ថែមនេះ ភាគីនៃជម្លោះអាចដាក់លក្ខខណ្ឌបាន។ ប្រសិនបើភាគីនៃជម្លោះពុំយល់ព្រមនោះទេ មជ្ឈត្តវិនិច្ឆ័យមិនត្រូវផ្តល់នូវសិទ្ធិបន្ថែមណាមួយទៅឲ្យភាគីទី៣ ចំពោះការចូលរួមក្នុងដំណើរការនៃមជ្ឈត្តវិនិច្ឆ័យឡើយ។

**វិធានទី៨៖ នីតិវិធីរបស់មជ្ឈត្តវិនិច្ឆ័យ**

១- មជ្ឈត្តវិនិច្ឆ័យ ត្រូវយកនីតិវិធីមកអនុវត្ត ដូចដែលមានចែងក្នុងវិធានទាំងនេះ។ មជ្ឈត្តវិនិច្ឆ័យអាចអនុម័តនីតិវិធីបន្ថែម ដែលពុំមានវិវាទជាមួយនឹងពិធីសារនេះ ឬវិធានទាំងនេះបាន។

២- ក្នុងអំឡុងពេល១៥ថ្ងៃចាប់ពីថ្ងៃដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានបង្កើតឡើង មជ្ឈត្តវិនិច្ឆ័យត្រូវកំណត់កាលវិភាគសម្រាប់នីតិវិធីរបស់ខ្លួន។ ដំណើរការនៃមជ្ឈត្តវិនិច្ឆ័យ ចាប់ពីពេលបង្កើតមជ្ឈត្តវិនិច្ឆ័យរហូតដល់ថ្ងៃចេញសេចក្តីសម្រេចចុងក្រោយ មិនត្រូវឲ្យលើសរយៈពេល៦ខែឡើយ ក្នុងករណីដែលភាគីនៃជម្លោះមិនបានឯកភាពគ្នា។

៣- ភាគីនៃជម្លោះនីមួយៗត្រូវមានឱកាសធ្វើការផ្តល់ជាលាយលក្ខអក្សរនូវអង្គហេតុនៃរឿងក្តី សេចក្តីសម្អាងហេតុ និងសេចក្តីសម្អាងហេតុតបរបស់ខ្លួនបាន។ កាលវិភាគដែលកំណត់ដោយមជ្ឈត្តវិនិច្ឆ័យ ត្រូវមានការកំណត់ពេលវេលាសំរាប់ភាគីនៃជម្លោះ និងភាគីទី៣ ដើម្បីដាក់ជូននូវសេចក្តីសម្អាងទាំងនោះ។

៤- កាលវិភាគកំណត់ដោយមជ្ឈត្តវិនិច្ឆ័យ ត្រូវផ្តល់ឱកាសឲ្យមានសវនាការយ៉ាងហោចណាស់មួយដងសម្រាប់ភាគីនៃជម្លោះ ដើម្បីបង្ហាញរឿងក្តីរបស់ខ្លួន ជូនមជ្ឈត្តវិនិច្ឆ័យ។

៥- មជ្ឈត្តវិនិច្ឆ័យត្រូវពិគ្រោះជាទៀងទាត់ជាមួយភាគីនៃជម្លោះ និងផ្តល់ពេលវេលាឲ្យបានគ្រប់គ្រាន់សម្រាប់ភាគីនៃជម្លោះស្វែងរកដំណោះស្រាយជម្លោះ ទៅតាមការឯកភាពរវាងគ្នានិងគ្នា។

**វិធានទី៩៖ ការផ្អាកដំណើរក្តី**

ភាគីជំលោះអាចយល់ព្រមឲ្យមជ្ឈត្តវិនិច្ឆ័យផ្អាកការងាររបស់ខ្លួន ក្នុងពេលណាមួយក៏បាន ក្នុងរយៈពេលមិនលើសពី១២ខែ ចាប់តាំងពីថ្ងៃដែលមានការព្រមព្រៀងឲ្យមជ្ឈត្តវិនិច្ឆ័យផ្អាកការងាររបស់ខ្លួនត្រូវបានធ្វើឡើង។ ក្នុងអំឡុងពេលនេះ ដំណើរការនៃមជ្ឈត្តវិនិច្ឆ័យដែលត្រូវបានផ្អាកនោះ ត្រូវចាប់ផ្តើមដំណើរការរបស់ខ្លួនឡើងវិញ ទៅតាមសំណើរបស់ភាគីណាមួយនៃជម្លោះ។ ក្នុងករណីដែលការងាររបស់មជ្ឈត្តវិនិច្ឆ័យត្រូវបានផ្អាកក្នុងថិរវេលាលើសពី១២ខែ មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ចប់ការងាររបស់ខ្លួន ប្រសិនបើមិនមានការព្រមព្រៀងរវាងភាគីនៃជម្លោះ។

**វិធានទី១០៖ ការដោះស្រាយ ឬ មូលដ្ឋានដទៃទៀតសម្រាប់ការបញ្ឈប់**

១- មុនពេលមានការសម្រេចណាមួយត្រូវបានធ្វើឡើង ប្រសិនបើភាគីនៃជម្លោះឯកភាពលើការដោះស្រាយជម្លោះ មជ្ឈត្តវិនិច្ឆ័យត្រូវចេញបទបញ្ជាឲ្យបញ្ចប់ដំណើរការមជ្ឈត្តវិនិច្ឆ័យ ឬត្រូវកត់ត្រាទុកដំណោះ

ស្រាយជម្លោះនោះក្នុងទម្រង់បែបបទនៃសេចក្តីសម្រេចរបស់មជ្ឈត្តនិច្ឆ័យ ចំពោះលក្ខខណ្ឌដែលមានការព្រមព្រៀងគ្នា ប្រសិនបើមានសំណើពីភាគីនៃជម្លោះ និងដោយមានការយល់ព្រមពីមជ្ឈត្តនិច្ឆ័យផង។ មជ្ឈត្តនិច្ឆ័យពុំមានកាតព្វកិច្ចក្នុងការផ្តល់ហេតុផលសម្រាប់ការចេញសេចក្តីសម្រេចដូចខាងលើទេ។

២- មុនពេលមានសេចក្តីសម្រេច ប្រសិនបើការបន្តដំណើរការនីតិវិធីមជ្ឈត្តកម្មលែងមានភាពចាំបាច់ ឬមិនអាចធ្វើបន្តទៅទៀត ដោយហេតុផលណាមួយដែលមិនមានចែងក្នុងវាក្យខណ្ឌទី១នៃវិធាននេះ នោះមជ្ឈត្តនិច្ឆ័យ ត្រូវជូនព័ត៌មានដល់ភាគីនៃជម្លោះ នូវគោលបំណងរបស់ខ្លួនក្នុងការចេញបទញ្ញា ដើម្បីបញ្ចប់ដំណើរការនៃមជ្ឈត្តនិច្ឆ័យ។ មជ្ឈត្តនិច្ឆ័យមានអំណាចចេញបទបញ្ជាបែបនេះ លើកលែងតែក្នុងករណីដែលភាគីនៃជម្លោះបានលើកឡើងនូវមូលដ្ឋានត្រឹមត្រូវសម្រាប់ការធ្វើការជំទាស់។

៣- ឯកសារច្បាប់ចម្លងនៃបទបញ្ជាបញ្ចប់នូវដំណើរនៃការមជ្ឈត្តនិច្ឆ័យ ឬសេចក្តីសម្រេចរបស់មជ្ឈត្តនិច្ឆ័យចំពោះលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា ដែលត្រូវបានចុះហត្ថលេខាដោយមជ្ឈត្តករ មជ្ឈត្តនិច្ឆ័យទទួលបន្ទុកជូនដំណឹងដល់ភាគីនៃជម្លោះ អគ្គលេខាធិការអាស៊ាន ភាគីទី៣ (ប្រសិនបើមាន) និងក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន (ចំពោះករណីដែលមជ្ឈត្តនិច្ឆ័យត្រូវបានចង្អុលបង្ហាញដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន)។

## វិធានទី១១៖ ការចំណាយ

១- ភាគីនីមួយៗនៃជម្លោះ ត្រូវទទួលបន្ទុកទៅលើការចំណាយសម្រាប់មជ្ឈត្តករដែលខ្លួនបានចាត់តាំងដោយអនុលោមតាមវាក្យខណ្ឌទី២នៃវិធានទី១ ឬដែលត្រូវបានតែងតាំងអគ្គលេខាធិការអាស៊ាន ដោយអនុលោមតាមវាក្យខណ្ឌទី៣នៃវិធានទី១ ហើយត្រូវទទួលបន្ទុកលើការចំណាយផ្ទាល់ខ្លួន និងចំណាយលើដំណើរការច្បាប់ផ្សេងៗទៀតផង។

២- ការចំណាយសម្រាប់ប្រធានមជ្ឈត្តនិច្ឆ័យ និងការចំណាយពាក់ពន្ធ័នឹងសកម្មភាពនៃដំណើរការមជ្ឈត្ត-និច្ឆ័យ ត្រូវចេញចំណាយក្នុងបដិភាគស្មើៗគ្នា រវាងភាគីនៃជម្លោះ។

## វិធានទី១២៖ ទីកន្លែងមជ្ឈត្តនិច្ឆ័យ

១- ទីកន្លែងនៃមជ្ឈត្តនិច្ឆ័យគឺត្រូវស្ថិតនៅឯលេខាធិការដ្ឋានអាស៊ាន ដែលមានទីតាំងនៅទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូនេស៊ី លើកលែងតែភាគីនៃជម្លោះឯកភាពគ្នាជ្រើសរើសរកទីកន្លែងផ្សេងពីនេះ។

២- មជ្ឈត្តនិច្ឆ័យ ត្រូវបើកកិច្ចប្រជុំដើម្បីពិគ្រោះយោបល់រវាងសមាជិករបស់ខ្លួននៅទីកន្លែងនៃមជ្ឈត្តនិច្ឆ័យ ឬនៅកន្លែងផ្សេងទៀតដែលអាចកាត់បន្ថយចំណាយកិច្ចប្រជុំនេះ។

៣- សេចក្តីសម្រេចត្រូវធ្វើឡើងនៅទីកន្លែងនៃមជ្ឈត្តនិច្ឆ័យ។

## វិធានទី១៣៖ ភាសា

១- ភាសារបស់មជ្ឈត្តនិច្ឆ័យ គឺភាសាអង់គ្លេស។

២- មជ្ឈត្តវិនិច្ឆ័យ អាចបញ្ជាថាឯកសារទាំងឡាយដែលដាក់ជូនក្នុងក្របខ័ណ្ឌនៃដំណើរការមជ្ឈត្តវិនិច្ឆ័យដែលធ្វើជាភាសាដើម ត្រូវមានភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស។

**វិធានទី១៤៖ សេចក្តីសម្រេចចិត្ត**

សេចក្តីសម្រេចចិត្តរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើឡើងដោយការបោះឆ្នោតតាមមតិភាគច្រើនរបស់មជ្ឈត្តករ។ នៅពេលដែលមិនមានមតិភាគច្រើនទេ នោះប្រធានមជ្ឈត្តវិនិច្ឆ័យត្រូវបោះឆ្នោតសម្រេច។

**វិធានទី១៥៖ ការខកខានមិនបង្ហាញវត្តមាន**

ប្រសិនបើភាគីណាមួយនៃជម្លោះមិនបានបង្ហាញវត្តមាននៅពីមុខអង្គមជ្ឈត្តវិនិច្ឆ័យ ឬខកខានមិនបានការពាររឿងក្តីរបស់ខ្លួន ភាគីម្ខាងទៀតនៃជម្លោះអាចស្នើអង្គមជ្ឈត្តវិនិច្ឆ័យឲ្យបន្តដំណើរការមជ្ឈត្តវិនិច្ឆ័យ ហើយចេញសេចក្តីសម្រេចរបស់ខ្លួនបាន។ អវត្តមាននៃភាគីនៃជម្លោះ ឬការខកខានក្នុងការការពាររឿងក្តីនៃភាគីជម្លោះ មិនអាចបង្កើតជាឧបសគ្គដល់ដំណើរការមជ្ឈត្តវិនិច្ឆ័យទេ។

**វិធានទី១៦៖ រឿងក្តីក្នុងក្របខ័ណ្ឌយុត្តាធិការនៃមជ្ឈត្តវិនិច្ឆ័យ**

១- អង្គមជ្ឈត្តវិនិច្ឆ័យត្រូវមានអំណាចគ្របដណ្តប់លើការជំទាស់ទាំងឡាយណាដែលខ្លួនមិនមានយុត្តាធិការបាន។

២- រឿងក្តីដែលអង្គមជ្ឈត្តវិនិច្ឆ័យមិនមានយុត្តាធិការទៅលើ ត្រូវលើកឡើងមិនឲ្យយឺតជាងកាលបរិច្ឆេទនៃសវនាការដំបូងរបស់អង្គមជ្ឈត្តវិនិច្ឆ័យទេ។

៣- ជាទូទៅ មជ្ឈត្តវិនិច្ឆ័យត្រូវសម្រេចលើរឿងក្តីណាដែលពាក់ព័ន្ធនឹងយុត្តាធិការរបស់ខ្លួនជាបញ្ហាបឋម។ ទោះជាយ៉ាងណាក៏ដោយ អង្គមជ្ឈត្តវិនិច្ឆ័យត្រូវដំណើរការមជ្ឈត្តវិនិច្ឆ័យ និងសម្រេចសេចក្តីលើរឿងក្តីប្រភេទនេះ នៅក្នុងការសម្រេចសេចក្តីចុងក្រោយរបស់ខ្លួន។

**វិធានទី១៧៖ សេចក្តីសម្រេច**

